





# ប៉ាននរកកម្ពុជាប្រជាធិបតេយ្យ

## ខែសីហា ឆ្នាំ១៩៧៨


អត្ថបទដោយ : ហ្គុនណា បឺយស្រ្តម

រូបថតដោយ : ហ្គុនណា បឺយស្រ្តម និង ហេដា អេកឺវ៉ល

# ឋាននរកកម្ពុជាប្រជាធិបតេយ្យ

## ខែសីហា ឆ្នាំ១៩៧៨

*អត្ថបទដោយ : ហ្គុនណា ប៊ឺយស្ត្រម*

*រូបថតដោយ : ហ្គុនណា ប៊ឺយស្ត្រម និង ហេដា អេកឺវ៉ល*

*រៀបចំជាភាសាខ្មែរដោយ : សាន់ កល្យាណ*

ឯកសារបកប្រែទី៧នៃមជ្ឈមណ្ឌលឯកសារកម្ពុជា

**◆ ហ្គុនណា បឺយស្ត្រម : ឋាននរកកម្ពុជាប្រជាធិបតេយ្យ ខែសីហា ឆ្នាំ១៩៧៨**

*◆ បកប្រែជាភាសាខ្មែរដោយ សាន់ កល្យាណ ◆ ពិនិត្យ និងកែសម្រួលដោយ ទេព ម៉េងឃាន ◆ ក្រាហ្វិក និង កុំព្យូទ័រការីដោយ គីម សុវណ្ណដានី ◆ រចនាក្រប និង តួសៀវភៅដោយ អ៊ីវ៉ែននី វ៉ុង ◆ បោះពុម្ពផ្សាយលើកទី១ នៅឆ្នាំ២០០៨ ដោយមជ្ឈមណ្ឌលឯកសារកម្ពុជាសហការជាមួយ វេទិកាប្រវត្តិសាស្ត្ររស់នៅប្រទេសស៊ុយអែដ ◆ រក្សាសិទ្ធិ ◆*

Translation Series No.7 ◆ Documentation Center of Cambodia

◆ Gunna Bergström: Living Hell, Democratic Kampuchea, August 1978
◆ Translated by Kalyan Sann ◆ Edited by Meng Khean Tep ◆ Graphic by Sovanndany Kim ◆ Cover and Book design by Double Happiness Creation, Inc. ◆ Published by Documentation Center of Cambodia and the Living History Forum in Sweden ◆ Printed in Cambodia, 2008 ◆ Copyright ◆


មជ្ឈមណ្ឌលឯកសារកម្ពុជា
*Searching for the truth.*
Documentation Center of Cambodia
P.O. Box 1110, Phnom Penh, Cambodia
Tel.: + 855 (23) 211-875
Fax.: + 855 (23) 210-358
Email: dccam@online.com.kh
Homepage: www.dccam.org


DISCLAMER
The views expressed in this paper are solely those of the author.
ទស្សនៈបញ្ចេញនៅក្នុងសៀវភៅនេះ គឺរបស់អ្នកនិពន្ធតែម្នាក់គត់ ។


ISBN - 9789995-06-01-52
លសខអ - ៩៧៨៩៩៩៥-០៦-០១-៥២
ISBN-9: 789995-060169
លសខអ-៩ : ៧៨៩៩៩៥-០៦០១៦៩

Printed in Cambodia

# អារម្ភកថា

នៅពេលដែលខ្មែរក្រហមកំពុងតែគ្រប់គ្រងប្រទេសកម្ពុជា ស្ទើរតែគ្មាននរណាម្នាក់នៅលោកខាងលិចត្រូវបានអនុញ្ញាតឲ្យចូលមកក្នុងប្រទេសកម្ពុជាឡើយ ។ ខ្ញុំបានដឹងអំពីរឿងនេះ ប៉ុន្មានខែបន្ទាប់ពី ប៉ុល ពត ដួលរលំពីអំណាច ។ ក្នុងឆ្នាំ ១៩៧៩ កាសែតដែលខ្ញុំធ្វើការជាមួយបានបញ្ជូនខ្ញុំទៅយកព័ត៌មានអំពីការដួលរលំរបស់ខ្មែរក្រហមនិងជនភៀសខ្លួនកម្ពុជា ។ តាមរយៈជនភៀសខ្លួនដែលកំពុងតែរងទុក្ខវេទនាស្ទើរស្លាប់ស្ទើររស់នៅព្រំដែនខ្មែរ-ថៃ ខ្ញុំបានដឹងអំពីការកាប់សម្លាប់ ដែលខ្មែរក្រហមបានប្រព្រឹត្តទៅលើប្រជាជនខ្លួនឯង ។ គ្មានអ្វីគួរឲ្យសង្ស័យទេថា មេដឹកនាំនៃរបបខ្មែរក្រហមមិនចង់ឲ្យនរណាម្នាក់មើលឃើញអ្វីៗដែលខ្លួនកំពុងតែធ្វើ ។

ថ្ងៃនេះ អានសៀវភៅរបស់ ហ្កុនណា បឺយស្រ្តម ខ្ញុំស្ងើចសរសើរគាត់និងមិត្តភក្តិរួមដំណើររបស់គាត់ចំពោះការខិតខំប្រឹងប្រែងធ្វើមិនដឹងមិនឮចំពោះអ្វីដែលគាត់បានឃើញនៅប្រទេសកម្ពុជាកាលពីឆ្នាំ១៩៧៨ ទាំងអស់នេះពីព្រោះតែគាត់ចង់ជឿជាក់ទៅលើ«បដិវត្តន៍» ។ តម្រុយបានបង្ហាញច្បាស់ក្រឡែត ចម្លើយរបស់មេដឹកនាំខ្មែរក្រហមមិនច្បាស់លាស់និងមិនគួរឲ្យអបអរសាទរទាល់តែសោះ ។

ហ្កុនណា និងខ្ញុំ មានអាយុស្របាលគ្នា ។ ដូចជាជនជាតិអាមេរិកមួយចំនួនធំដែរ ខ្ញុំបានប្រឆាំងយ៉ាងខ្លាំងក្លាចំពោះសង្គ្រាមនៅវៀតណាម ។ ពេលដែលខ្ញុំរៀននៅសកលវិទ្យា-ល័យ ខ្ញុំបានចូលរួមធ្វើបាតុកម្មប្រឆាំងនឹងប្រធានាធិបតីនិចសុន ហើយនៅពេលដែលខ្ញុំចាប់ផ្តើមធ្វើការងារជាអ្នកកាសែត ខ្ញុំបានសរសេរអត្ថបទអំពីរឿងនេះ ។

អ្វីដែលខ្ញុំចង់និយាយនៅទីនេះគឺថា ខ្ញុំនិងប្រជាជននៅលោកខាងលិចរាប់លាននាក់ក៏ខឹងសម្បាចំពោះសង្គ្រាមនៅឥណ្ឌូចិនមិនតិចជាងកំហឹងរបស់ ហ្កុនណា និងមិត្តរួមការងាររបស់គាត់ដែរ ។ ក៏ប៉ុន្តែ នៅពេលដែលខ្ញុំបានឮព័ត៌មានដំបូងបំផុតអំពីអ្វីដែលខ្មែរក្រហមកំពុងតែធ្វើនៅក្នុងខួរក្បាលរបស់ខ្ញុំ ខ្ញុំមើលឃើញអំពើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ពិតមែនសហរដ្ឋអាមេរិកបានធ្វើខុស ក៏ប៉ុន្តែយើងមិនអាចប្រើប្រាស់កំហុសនេះជាលេសដើម្បីបិទបាំងអំពើឧក្រិដ្ឋដទៃទៀតបានទេ ។

ហ្កុនណា បានកត់សម្គាល់ឃើញចំណុចទាំងអស់នេះក្នុងអំឡុងពេលទស្សនកិច្ចរបស់គាត់នៅឆ្នាំ១៩៧៨ ដែលលើសពីគ្រប់គ្រាន់ដើម្បីឲ្យគាត់កើតមានការមន្ទិលសង្ស័យ ។ គាត់បានសរសេរថា តើវាយុត្តិធម៌ដែរឬទេដែលចាត់ទុកប្រជាជនទីក្រុងជាសត្រូវនិងបង្ខំឲ្យប្រជាជនទាំងនោះចាកចេញពីផ្ទះសម្បែងដែលខ្លួនកំពុងតែរស់នៅ? ចុះគំនិត “ដ៏ឆ្កួតលេលា” ដែលចង់បំប្លែងវប្បធម៌ដែលមានចំណាស់រាប់ពាន់ឆ្នាំមកហើយឲ្យទៅជាខ្មោច«មនុស្សថ្មី»តែក្នុងអំឡុងពេលពីរ-បីឆ្នាំ? ចុះមន្ទីរសុខភាពក្លែងក្លាយនៅភូមិ-ឃុំ ឬថ្នាំដែលកសិករផលិតអំពីឫសឈើ មើមឈើ ខណៈពេលដែលគ្មានថ្នាំប៉េនីស៊ីលីន? តើត្រូវពន្យល់យ៉ាងដូចម្តេចចំពោះករណីដែលកុមារតូចៗឬក្មេងកំព្រាដែលត្រូវបានបង្ខំឲ្យធ្វើការងារជំនួសឲ្យការបញ្ជូនទៅសាលារៀន?

មានតែមនុស្សប៉ុន្មាននាក់ប៉ុណ្ណោះដែលបានទទួលការអនុញ្ញាតឲ្យចូលមកក្នុងប្រទេសកម្ពុជា ហើយវាគួរឲ្យអាម៉ាស់ណាស់ដែលភ្ញៀវប៉ុន្មាននាក់នោះមិនអាចស្វែងយល់អំពីការពិតទាំងអស់នេះ ។

ខ្មែរក្រហមមិនបានអញ្ជើញខ្ញុំនិងអ្នកឯទៀតទៅធ្វើទស្សនកិច្ចនៅកម្ពុជាទេ ។ យើងមិនមែនជាសមាជិកសមាគមមិត្តភាពស៊ុយអែដ-កម្ពុជា ។ យើងអាចនឹងមិនត្រឡប់មកវិញជាមួយនឹងទស្សនវិស័យគាំទ្រខ្មែរក្រហម ។ខ្ញុំឧបមាថា ប្រសិនបើខ្ញុំបានឃើញការពិតទាំងអស់ដូចដែលបានបង្ហាញនៅក្នុងសៀវភៅនេះ ខ្ញុំពិតជាមានការយល់ឃើញផ្សេងពី ហ្កុនណា ក៏ប៉ុន្តែខ្ញុំមិនប្រាកដដែរ ។ ខ្ញុំប្រហែលជាអាចយល់ឃើញដូចជាគាត់ដែរនៅក្នុងអំឡុងពេលដូចគ្នា ។

តើអាចនឹងមានរឿងហេតុអ្វីកើតឡើងប្រសិនបើ ហ្កុនណា ត្រឡប់មកវិញហើយបើកកាយអំពីធាតុពិតរបស់ខ្មែរក្រហម? បើពិនិត្យមើលស្ថានភាពរបស់ពិភពលោកកាលពីពេលនោះ វាដូចជាមិនទំនងថាអាចនឹងមានប្រទេសណាមួយលូកដៃទៅបញ្ឈប់វិនាសកម្ម បើទោះបីជាការពិតបានលេចចេញច្បាស់ក្រឡែតក៏ដោយ ។

ទោះជាយ៉ាងណាក៏ដោយ រាល់ការខិតខំប្រឹងប្រែងដើម្បីបង្វែរពិភពលោកឲ្យប្រឆាំងនឹងរបបប្រល័យពូជសាសន៍ ប្រហែលជាអាចដាស់ស្មារតីមេដឹកនាំខ្មែរក្រហម បង្អាក់ដំណើរអ្នកគាំទ្រទាំងអស់ និងសង្គ្រោះជីវិតមនុស្សបានមួយចំនួន ។

ចូអែល ប្រ៊ីងគ្លី
សាកលវិទ្យាល័យ ស្តេនហ្វត

# សេចក្តីផ្តើម

ខ្ញុំបានទៅធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជាពីថ្ងៃទី១៧ ដល់ថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៧៨ ។ នៅពេលនោះ ប្រទេសកម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម និងមានឈ្មោះជាផ្លូវការថា«កម្ពុជាប្រជាធិបតេយ្យ» ។ ប៉ុល ពត គឺជានាយករដ្ឋមន្ត្រី ។ គណៈប្រតិភូរបស់យើងដែលមានសមាជិកបួននាក់មានប្រភពមកពី«សមាគមមិត្តភាពស៊ុយអែដ-កម្ពុជា» ។ យើងស្ថិតនៅក្នុងចំណោមគណៈប្រតិភូដែលធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យជាលើកដំបូងបំផុតចាប់តាំងពីខ្មែរក្រហមឡើងកាន់អំណាច ។

កាលពីពេលនោះ ខ្ញុំគឺជាអ្នកគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យ ។ ឥឡូវនេះ ពេលដែលខ្ញុំមានការយល់ដឹងប្រសើរជាងមុន ខ្ញុំមើលទៅសាមសិបឆ្នាំក្រោយវិញ និងខំប្រឹងស្វែងយល់អំពីដំណើរទស្សកិច្ចនៅពេលនោះខ្ញុំយល់ឃើញថា កាលនោះយើងមិនគួរធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យទាល់តែសោះ ពីព្រោះនោះជាផ្នែកមួយនៃការឃោសនានយោបាយរបស់ខ្មែរក្រហម ។ ខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់ដែលបានចូលរួមក្នុងដំណើរទស្សកិច្ចនោះ ក៏ប៉ុន្តែខ្ញុំមិនអាចត្រឡប់ក្រោយវិញបានទេ ។ ខ្ញុំអាចព្យាយាមរៀនសូត្រអំពីបទពិសោធន៍នោះ ។ ខ្ញុំសង្ឃឹមថា ពិព័រណ៍អំពីរូបថតដែលយើងបានថតកាលពីពេលនោះជាមួយនឹងការពិពណ៌នាអំពីការយល់ឃើញរបស់ខ្ញុំ គួបផ្សំនឹងការឆ្លុះបញ្ចាំងរបស់សាធារណជន នឹងបង្កើតឲ្យមានការយល់ដឹងប្រសើរជាងមុនអំពីរបបខ្មែរក្រហម ។ ជាងនេះទៅទៀត ពិព័រណ៍នេះនឹងបង្ហាញអំពីរបៀបដែលមនោគមន៍វិជ្ជាបោកប្រាស់អាចធ្វើឲ្យមនុស្សជឿងប់ងុល សូម្បីតែជឿថាខ្លួនឯងកំពុងតែប្រយុទ្ធដើម្បីបុព្វហេតុដ៏ត្រឹមត្រូវ ។

ខ្ញុំធ្លាប់បានធ្វើការនៅក្នុងចលនាប្រឆាំងនឹងសង្គ្រាមនៅក្នុងប្រទេសកម្ពុជានិងវៀតណាម នៅអំឡុងទសវត្សរ៍ឆ្នាំ១៩៧០ ។ នៅក្នុងរបបខ្មែរក្រហម យើងគិតថាយើងបានឃើញបដិវត្តន៍ដ៏បរិសុទ្ធមួយដែលមិនស្ថិតនៅក្រោមឥទ្ធិពលរបស់មហាអំណាចបរទេស ។ ខ្លួនខ្ញុំផ្ទាល់ក៏ដូចជាប្រជាជនស៊ុយអែដមួយចំនួននៅក្នុងជំនាន់របស់ខ្ញុំ បានទទួលស្គាល់បដិវត្តន៍ចិនរបស់ ម៉ៅ សេទុង ប៉ុន្តែនៅពេលដែលយើងបានអានអំពីបដិវត្តន៍កម្ពុជា យើងយល់ថាយើងបានរកឃើញបដិវត្តន៍មួយដែលប្រសើរជាងបដិវត្តន៍របស់ចិនទៅទៀត គឺជាបដិវត្តន៍មួយដែលស្មើភាព គ្មានការគាបសង្កត់ គ្មានទាសភាព និងដែលព្យាយាមចៀសវាងកំហុសឆ្គង ដែលបដិវត្តន៍កុម្មុយនីស្តពីមុនៗធ្លាប់ឆ្លងកាត់ ។

មួយរយៈក្រោយមក យើងបានស្តាប់និងអានរឿងរ៉ាវអំពីការសម្លាប់និងការគាបសង្កត់ ។ យើងមិនចង់ជឿទាល់តែសោះ ។ ប្រហែលជាមានរឿងរ៉ាវមួយចំនួន ជាការពិត ក៏ប៉ុន្តែយើងអាចដោះសាថានោះបណ្តាលមកពីភាពច្របូកច្របល់ក្រោយពីសង្គ្រាម ។ មិនយូរទេ កម្ពុជានឹងធ្វើឲ្យសុបិនក្លាយជាការពិតនូវបដិវត្តន៍មួយដែលគួរឲ្យស្ងើចសរសើរ និងខុសពីបដិវត្តន៍ដទៃទៀត ។

ឥឡូវនេះខ្ញុំទើបតែដឹងថា សូម្បីតែនៅមុនដំណើរទស្សនកិច្ចរបស់យើង មានភស្តុតាងជាច្រើនដែលបញ្ជាក់ការពិតនៅប្រទេសកម្ពុជាអំពីការសម្លាប់ ការគាបសង្កត់ និងការធ្វើទារុណកម្ម ប៉ុន្តែយើងមិនជឿ ។ បន្ទាប់មកយើងត្រូវបានអញ្ជើញទៅប្រទេសកម្ពុជាដើម្បីមើលដោយផ្ទាល់ភ្នែក ។ រូបថតទាំងប៉ុន្មានដែលអ្នកទាំងអស់គ្នាកំពុងតែមើលនេះគឺជាអ្វីដែលយើងបានឃើញ ។ ជាការពិតណាស់ដែលយើងមិនបានទៅឃើញគុកទួលស្លែងដែលខ្មែរក្រហមរក្សាជាសម្ងាត់ និងមិនបានឃើញអំពើសាហាវឃោរឃៅ ។ យើងមិនចេះភាសាខ្មែរ យើងពឹងផ្អែកតែទៅលើមគ្គុទ្ទេសក៍ ខ្មែរក្រហមដែលមិនអនុញ្ញាតឲ្យយើងសម្រាកពេលយប់នៅឯសហករណ៍ ក៏ប៉ុន្តែរូបភាពទាំងនេះ គួបផ្សំនឹងទស្សនៈម៉ៅនិយមរបស់យើងធ្វើឲ្យយើងមើលឃើញតែអ្វីដែលយើងចង់ឃើញ ។ នៅក្នុងពិព័រណ៍នេះ លោកអ្នកនឹងឃើញដំណើរទស្សនកិច្ចរបស់យើង ឃើញអ្វីដែលយើងបានឃើញ និងឆ្លុះបញ្ចាំងការយល់ឃើញរបស់ខ្ញុំពីពេលនោះនិងពេលបច្ចុប្បន្ន ។

យើងត្រូវតែរៀនសូត្រពីបទពិសោធន៍ប្រវត្តិសាស្ត្រ ទើបរឿងរ៉ាវដូចគ្នានេះមិនកើតឡើងជាថ្មីម្តងទៀត ។

ហុនណា បីយស្រ្តម
វ៉ូលិនធូណា, ស្តុកខូម, ខែមេសា ឆ្នាំ១៩៧៨

# រូបថតកម្ពុជាប្រជាធិបតេយ្យក្នុងខែសីហា ឆ្នាំ១៩៧៨




ខ្សែបន្ទាត់ពណ៌ក្រហមគឺជាផ្លូវដែលគណៈប្រតិភូ
ស៊ុយអែដធ្វើទស្សនកិច្ចនៅក្នុងខែសីហា ឆ្នាំ១៩៧៨

## បុគ្គលិកបម្រើគណៈប្រតិភូកាលពីឆ្នាំ១៩៧៨



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ប្រហែលជាមាននរណាម្នាក់ធ្លាប់រស់នៅក្នុងផ្ទះនេះពីមុនមក ហើយត្រូវខ្មែរក្រហមជម្លៀសចេញទៅ។ តើយុត្តិធម៌ដែរឬទេ? តើអ្នកទាំងអស់នោះជាសត្រូវឬ? បើចាញ់សង្គ្រាមហើយមិនគ្រប់គ្រាន់មែនទេ ហេតុអ្វីក៏ក្លាយទៅជា សត្រូវដោយសារតែមានប្រវត្តិជាអ្នកទីក្រុង?

ខ្ញុំមានអារម្មណ៍ដូចជាកំពុងតែដេកលើគ្រែរបស់អ្នកដទៃ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

យុវជនទាំងនេះទៅណាអស់ហើយ? តើគាត់នៅរស់រានមានជីវិតដែរឬទេ? តើមានរឿងអ្វីកើតឡើងចំពោះគាត់នាពេលក្រោយមក?



ស្ពានជ្រោយចង្វារដែលដាច់ដោយសារការ
ទម្លាក់គ្រាប់បែក (ភ្នំពេញ)

# ទីក្រុងភ្នំពេញក្នុងខែសីហា ឆ្នាំ១៩៧៨




## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

តើការដែលទុកចោលរបស់ដែលប្រើប្រាស់បានឲ្យខូចខាតបែបនេះមិនជាការខ្ជះខ្ជាយធនធានដែលមានស្រាប់ទេឬ? ក៏ប៉ុន្តែយើងត្រូវតែជឿជាក់លើអ្នកដឹកនាំ ។ អ្នកដឹកនាំពិតជាមានមូលហេតុក្នុងការធ្វើបែបនេះ ។ ការជម្លៀសប្រជាជនបែបនេះគឺជាការរំលោភសិទ្ធិមនុស្ស ។ យើងគ្រាន់តែសង្ឃឹមថាបដិវត្តន៍នេះនឹងមានភាពចាស់ទុំជាងមុន ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

មើលទៅទំនងជាមានអ្វីខុសនៅក្នុងគំនិតរបស់មេដឹកនាំខ្មែរក្រហមដែលភ័ន្តច្រឡំរវាងការបែងចែកវណ្ណៈនិងការចាត់ទុកអ្នកទីក្រុងជាសត្រូវ ។

## ការយល់ឃើញដែលត្រូវហាមឃាត់កាលពីពេលនោះ

បដិវត្តន៍នេះពិតជាយល់ខុសអំពីកុម្មុយនីស្តរបស់ម៉ាក្ស ។



ចេតិយនៅក្នុងបរិវេណព្រះបរមរាជវាំង

# ព្រះបរមរាជវាំង



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

យើងបានទៅទស្សនាព្រះវិហារព្រះកែវមរកតដែលមើលទៅដូចជានៅល្អស្អាតដដែលផុយពីពាក្យចចាមអារ៉ាម ។ យើងបានសុំអនុញ្ញាតជួបសម្តេច សីហនុ ប៉ុន្តែត្រូវបដិសេធ ។ តើសម្តេច សីហនុ ស័ក្តិសមនឹងទទួលការប្រព្រឹត្តបែបនេះចំពោះព្រះអង្គដែរឬទេ?

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ការប្រព្រឹត្តបែបនេះចំពោះសម្តេច សីហនុ គឺខ្វះសេចក្តីគោរព ។

# ទីក្រុងភ្នំពេញដែលគ្មានមនុស្សរស់នៅ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ការជម្លៀសប្រជាជនចេញពីទីក្រុងពិតជាបានបណ្តាលឲ្យប្រជាជនជួបនឹងទុក្ខវេទនាច្រើនជាមិនខាន បូករួមទាំងអ្នកដែលធ្លាប់គាំទ្របដិវត្តន៍ផង ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

មេដឹកនាំខ្មែរក្រហមកុហកប្រជាជនខ្លួនឯងនិងពិភពលោកអំពីការជម្លៀសនិងអំពីរឿងរ៉ាវផ្សេងៗទៀត ។

ទីក្រុងភ្នំពេញ
ក្នុងថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៨





## ដំណើរទស្សនកិច្ចតាមទូកនៅទីក្រុងភ្នំពេញ
## ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៨

### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ការជិះទូកនេះនាំឲ្យយើងមើលឃើញការខូចខាតជាច្រើនដែលបណ្ដាលមកពីសង្គ្រាម ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើអ្នកដែលជិះទូកជាមួយយើងទាំងប៉ុន្មានទៅជាយ៉ាងណានៅពេលក្រោយមក? ប្រសិនបើអ្នកទាំងនោះនៅរស់ តើគាត់យល់ឃើញដូចម្ដេចចំពោះអ្វីដែលបានកើតឡើងកាលពីពេលនោះ?

ប្រជាជនជាច្រើននាក់កំពុងតែស្ដាប់នៅពីក្រោយអ្វីៗដែលយើងមើលឃើញ ។

លេណដ្ឋានរបស់ លន់ ណុល
(បើតាមមគ្គុទ្ទេសក៍ប្រាប់យើង)



## ផ្នែកមួយនៃទីប្រជុំជនស្គន់ (បើតាមការប្រាប់របស់មគ្គុទ្ទេសក៍)



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ដើម្បីយល់អំពីប្រទេសកម្ពុជានិងអំពីអ្វីដែលកើតឡើងនៅទីនេះ យើងមិនអាចធ្វើមិនដឹងមិនឮអំពីសង្គ្រាមកាលពីមុនឆ្នាំ ១៩៧៥ ខណៈដែលសហរដ្ឋអាមេរិកទម្លាក់គ្រាប់បែករាប់ពាន់តោនមកលើប្រទេសកម្ពុជានោះឡើយ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

យើងមិនអាចទម្លាក់កំហុសទាំងអស់ទៅលើសហរដ្ឋអាមេរិក ហើយបណ្តោយឲ្យខ្មែរក្រហមរួចខ្លួនពីការទទួលខុសត្រូវនោះទេ ប៉ុន្តែយើងក៏មិនត្រូវបណ្តោយឲ្យសហរដ្ឋអាមេរិករួចខ្លួនពីការទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានធ្វើនោះដែរ ។

អគារបាក់បែកនៅកំពង់ចាម



# ការឈប់សំចតនៅតាមផ្លូវដើម្បីឱ្យគណៈប្រតិភូថតរូបនិងថតវីដេអូ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

គណៈប្រតិភូអាចសុំឈប់ដើម្បីថតរូបនិងវីដេអូនៅទីណាក៏បានតាមតែយើងត្រូវការ ។ នេះមិនមានន័យថាអ្វីៗទាំងអស់ត្រូវបានរៀបចំសម្រាប់តែបង្ហាញយើងនោះទេ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

អ្វីៗដែលយើងបានឃើញពិតជាខុសអំពីពាក្យចចាមអារ៉ាមដែលយើងបានឮអំពីប្រទេសកម្ពុជា ប៉ុន្តែនៅមានរឿងរ៉ាវជាច្រើនទៀតដែលយើងមិនបានឃើញ ។ រឿងរ៉ាវដែលជនភៀសខ្លួនកម្ពុជាបាននិយាយពិតជាដូចគ្នាទៅនឹងអ្វីដែលយើងបានឃើញនៅពេលនោះ ។

### ការយល់ឃើញបន្ថែមនៅក្នុងពេលនោះ

មគ្គុទ្ទេសក៍និយាយប្រាប់យើងអំពីការបង្កើត«មនុស្សថ្មី» ។ សុបិនបែបនេះមាននៅគ្រប់បដិវត្តន៍ដែលកើតពីពេលមុនៗមក គឺជាគំនិតដ៏ក្មេងខ្ចីដែលចង់ឲ្យមានកំណែទម្រង់ឆាប់រហ័សជ្រុលពេកខណៈដែលវប្បធម៌ដើមចាក់ឫសរាប់ពាន់ឆ្នាំមកហើយ ។ ខ្ញុំមិនជឿថាខ្មែរក្រហមអាចបង្កើត«មនុស្សថ្មី»បានក្នុងរយៈពេលបីឆ្នាំនោះទេ ។ ហេតុអ្វីក៏ខ្មែរក្រហមយល់ថាខ្លួនអាចធ្វើបាន?

## កងចល័តកំពុងសាងសង់ទំនប់ទឹកខ្នាតតូចនៅភាគខាងជើងទីក្រុងភ្នំពេញ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ដោយសារតែយើងធ្លាប់បានឮរឿងរ៉ាវអំពីការកាប់សម្លាប់អ្នកទីក្រុង យើងចង់ស៊ើបមើលថាតើជាការពិតដែរឬទេ ។ យើងសុំអនុញ្ញាតនិយាយជាមួយនរណាម្នាក់ដែលមកពីទីក្រុង ។ មគ្គុទ្ទេសក៍ប្រាប់យើងថាមានអ្នកមកពីទីក្រុងកំពុងតែធ្វើការនៅទីនេះ ប៉ុន្តែអ្នកទាំងនោះរវល់បំពេញភារកិច្ចជូនបដិវត្តន៍ មិនមានពេលវេលាជួបនិយាយជាមួយយើងទេ ។ ខ្ញុំមិនជឿទាល់តែសោះ!

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

កងចល័តនេះមើលទៅដូចជាផ្នែកមួយនៃគម្រោងការដ៏ធំមួយ ក៏ប៉ុន្តែអ្នករៀបចំគម្រោងនោះភ្លេចគិតអំពីជីវិតនិងសុខុមាលភាពរបស់មនុស្សម្នាក់ៗ ។ មើលទៅគម្រោងនោះ ហាក់ដូចជាលេសមួយ ដើម្បីបិទបាំងអំពើរំលោភសិទ្ធិមនុស្ស ។

### ការយល់ឃើញដែលត្រូវហាមឃាត់កាលពីពេលនោះ

ចុះបើរឿងរ៉ាវអំពីការសម្លាប់អ្នកទីក្រុងគឺជាការពិតទៅវិញ តើវាទៅជាយ៉ាងដូចម្តេចទៅវិញ?

# សាឡាងឆ្លងកាត់ទន្លេនៅភាគខាងជើងទីក្រុងភ្នំពេញ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

មនុស្សនៅទីនេះហាក់ដូចជាទំនេរច្រើន និងមើលទៅដូចជាគ្មានការភិតភ័យ មិនដូចជាពាក្យចចាមអារ៉ាមដែលនិយាយអំពីការកាប់សម្លាប់និងការគំរាមកំហែង ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើអ្នកទាំងអស់នេះជាប្រជាជនមូលដ្ឋានដែលខ្មែរក្រហមជ្រើសរើសមកទីនេះឬ? ឬក៏មានតែអ្នកដែលអង្គការទុកចិត្តទុកជើមទើបបានទទួលការអនុញ្ញាតឲ្យឆ្លងសាឡាង?

# កងចល័តនារីរង់ចាំថយន្តក្រុង
# នៅចំណតសាឡាងខាងជើងទីក្រុងភ្នំពេញ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

នៅក្នុងកងចល័តនេះ យុវជននិងយុវនារីនៅដាច់ដោយឡែកពីគ្នា ។ តើការងារនៅទីនេះប៉ុន្មានភាគរយជាការងារស្ម័គ្រចិត្ត ហើយប៉ុន្មានភាគរយជាការបង្ខិតបង្ខំ?

ក៏ប៉ុន្តែទាំងនេះប្រហែលជាដំណាក់កាលអន្តរកាលដើម្បីឆ្ពោះទៅរកកម្ពុជាដ៏រុងរឿងមហាអស្ចារ្យ ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ប្រហែលជាមេដឹកនាំខ្មែរក្រហមនៅតែបារម្ភអំពីសង្គ្រាម ។ អ្វីៗទាំងអស់ត្រូវបានរៀបចំដោយគ្មានការត្រិះរិះពិចារណាអំពីការបាត់បង់ជីវិតរបស់ប្រជាជន ។ បដិវត្តន៍នេះដឹកនាំដោយមនុស្សមួយក្រុមតូចនិងគ្មានការគាំទ្រទាល់តែសោះ ។



## នៅភាគខាងជើងទីក្រុងភ្នំពេញ កងចល័តកុមារនិងយុវនារីចេញដំណើរទៅធ្វើការ ដោយជិះរថយន្តក្រុង

### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

អ្នកទាំងនេះមើលទៅដូចជាមានសុខភាពល្អនិងសប្បាយរីករាយ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ប្រហែលជាអ្នកដែលយើងជួបសុទ្ធតែជាប្រជាជនមូលដ្ឋាននិងសមាជិកខ្មែរក្រហមដែលមានការរស់នៅប្រសើរជាងប្រជាជនថ្មី ។

## ស្ត្រីច័យកណ្ដាលធ្វើការនៅក្នុងវាលស្រែរបស់សហករណ៍



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ការបង្កើតសហករណ៍ហើយឲ្យមនុស្សធ្វើការរួមគ្នាបែបនេះ គឺជាមធ្យោបាយក្នុងការចិញ្ចឹមប្រជាជនទូទាំងប្រទេស ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ចំណងសាមគ្គីភាពរវាងមនុស្សកើតចេញអំពីទឹកចិត្តមិនមែនអំពីការគំរាមកំហែង បង្ខិតបង្ខំ និងបំបាក់កម្លាំងនោះទេ ។



ស្ត្រីច័យកណ្តាលធ្វើការនៅក្នុងខាលស្រែ

# កុមារសហករណ៍ដេញចាបក្នុងស្រែ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

កាលពីមុននៅប្រទេសស៊ុយអែដ កុមារក៏ធ្វើការនៅក្នុងកសិដ្ឋានដែរ ទម្រាំតែយើងមានលទ្ធភាពបញ្ជូនកុមារទៅសាលារៀន ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ខ្ញុំដឹងថាកុមារមួយចំនួនបាត់បង់ឪពុកម្តាយ និងបាត់បង់ឱកាសលូតលាស់ដោយផាសុកភាព ។

## ការទទួលទានបាយរួម



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

នៅសហករណ៍នេះមើលទៅប្រជាជនម្នាក់ៗ មានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ។ ធ្វើការងាររួមគ្នាហើយបែងចែកផលស្មើៗគ្នា ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

នេះគឺជាការបង្ខិតបង្ខំដែលផ្ទុយទៅនឹងគោលបំណងរបស់ប្រជាជន និងបង្កឲ្យមានទុរ្ភិក្សនិងភាពក្រីក្រ ។ រូបភាពទាំងអស់នេះបង្ហាញឲ្យឃើញអំពីអំណាចយោធានៅក្នុងប្រទេសដែលប្រជាជនត្រូវបានចាត់ទុកត្រឹមតែជាតួលេខ ។

### ការយល់ឃើញដែលត្រូវហាមឃាត់កាលពីពេលនោះ

កន្លែងនេះមើលទៅដូចជាជំរំយោធា ។ ហេតុអ្វីក៏កុមារទាំងនេះអង្គុយដាច់ពីមនុស្សចាស់ ហើយស្ត្រីនិងបុរសអង្គុយផ្សេងពីគ្នា? តើនេះជាការបង្ខិតបង្ខំឬ?

ការទទួលទានបាយរួម



# ក្រុមគ្រួសារនេះមកពីទីក្រុងភ្នំពេញ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

នៅពេលបានជួបក្រុមគ្រួសារដែលមកពីទីក្រុងភ្នំពេញបែបនេះបញ្ជាក់ច្បាស់ថាគ្មានការកាប់សម្លាប់ប្រជាជនទីក្រុងទេ ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ខ្ញុំនៅតែមិនទាន់យល់និងពិបាកពន្យល់ការជួបគ្នាដ៏ចម្លែកមួយនេះ ។ នៅសុខៗស្រាប់តែខ្មែរក្រហមនាំយើងទៅជួបអ្នកមកពីទីក្រុងភ្នំពេញ ។សមាជិកម្នាក់នៃគណៈប្រតិភូរបស់យើងធ្លាប់ស្គាល់បុរសម្នាក់នេះ និងធ្លាប់បានជួបគាត់មួងកាលពីឆ្នាំ ១៩៦៧ ។ បុរសនេះពិតជាអ្នករស់នៅទីក្រុងភ្នំពេញមែន ។ ហេតុអ្វីក៏ចៃដន្យម្ល៉េះ!

យើងមិនបានដឹងអ្វីទាំងអស់អំពីជីវិតរបស់គាត់ ព្រោះយើងមិនចេះភាសាខ្មែរ ។ តើការបកប្រែពិតជាត្រឹមត្រូវដែរឬទេ?

បុរសនេះនិយាយប្រាប់យើងជាភាសាបារាំងថា គាត់និយាយការពិត ។ ក៏ប៉ុន្តែការពិតនោះគឺថា គ្មាននរណាម្នាក់អាចនិយាយអំពីការពិតបានទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

កសិករកំពុងឃ្វាលគោ





## កុមារចាប់កង្កែបនៅតាមខាលស្រែ

### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

កុមារទាំងនេះមើលទៅដូចជាមិនអីទេ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

មិនមែនកុមារទាំងអស់សុទ្ធតែមានសុខភាពល្អបែបនេះទេ ។

# រទេះសេះ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

រូបភាពនេះមិនដូចជាអ្វីដែលនិយាយថាមនុស្សទាំងអស់ស្លៀកពាក់ដូចៗគ្នា ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើបុរសម្នាក់នេះជានរណាដែលបានទទួលការទុកចិត្តឲ្យធ្វើដំណើរតាមផ្លូវតែម្នាក់ឯង? តើនេះជាការជួបដោយចៃដន្យឬក៏ជាគម្រោងដែលរៀបចំទុកជាមុន?

# អតីតចំណតរថយន្តក្រុងនៅកំពង់ចាម



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

តើការជម្លៀសប្រជាជនបែបនេះត្រឹមត្រូវដែរឬទេ?

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

កង្វះខាតរូបិយបណ្ណនិងមធ្យោបាយដឹកជញ្ជូនសាធារណៈ បណ្តាលឲ្យមនុស្សម្នាក់ៗជាប់គាំងមិនអាចធ្វើអ្វីកើត ។ ប្រជាជនមិនអាចធ្វើដំណើរ និងមិនអាចទិញជូរម្ហូបអាហារ ។ បើមើលពីដំបូង ការលុបបំបាត់រូបិយបណ្ណមានសារសំខាន់មែន ក៏ប៉ុន្តែវាបង្កើតឲ្យមានទោសភាព ។

## យុវនារីកំពុងធ្វើការងារនៅអតីតចំណតរថយន្តក្រុងនៅកំពង់ចាម



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

យុវនារីទាំងនេះមើលទៅមិនសូវជារវល់ប៉ុន្មានទេ ហើយថែមទាំងសប្បាយចិត្តទៀតផង ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើយុវនារីទាំងនេះសប្បាយចិត្តដែលត្រូវបានអង្គការលើកតម្កើង? តើយុវនារីទាំងនេះមានសេរីភាពប៉ុណ្ណាក្នុងការសម្រេចចិត្តដោយខ្លួនឯង?



វាលស្រែនៅតាមផ្លូវពីកំពង់ចាម

# រោងចក្រកែច្នៃកៅស៊ូនៅកំពង់ចាម



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ពាក្យស្លោកដូចដែលយើងឃើញចង់នៅទីនេះ  មិនមានច្រើនទេ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តាមមើលទៅការឃោសនានយោបាយច្រើនតែតាមរយៈសុន្ទរកថានៅក្នុងអង្គប្រជុំ ។  ព្រឹត្តិបត្រនិងឯកសារដែលបោះពុម្ពផ្សាយមិនមែនសម្រាប់ប្រជាជនទេ ។

# កម្មករនៅក្នុងរោងចក្រកែច្នៃជ័រកៅស៊ូ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

តើការងារនៅទីនេះមិនបណ្ដាលឲ្យប៉ះពាល់សុខភាពទេឬ? ទីនេះប្រើប្រាស់សុទ្ធតែជាតិគីមី ។

រោងចក្រនេះបង្ហាញឲ្យឃើញថាកម្ពុជាប្រជាធិបតេយ្យមិនមែនដើរថយក្រោយដូចការរិះគន់មួយចំនួននោះទេ ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើជ័រកៅស៊ូដែលកែច្នៃរួចហើយមានគុណភាពដូចម្ដេចដែរ? ខ្ញុំមិនដឹង!

## រោងចក្រកែច្នៃជ័រកៅស៊ូ





កម្មករនៅក្នុងរោងចក្រកែច្នៃជ័រកៅស៊ូ

ស្ត្រីវ័យកណ្តាលធ្វើការនៅក្នុងរោងចក្រ
ផលិតឥដ្ឋ



# រោងចក្រផលិតឱសថនៅកំពង់ចាម




## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

រោងចក្រនេះក៏បង្ហាញឲ្យឃើញថាការនិយាយមិនល្អមួយចំនួនអំពីកម្ពុជាប្រជាធិបតេយ្យគឺមិនត្រឹមត្រូវ ។ កម្ពុជាមានមន្ទីរពេទ្យនិងមានថ្នាំពេទ្យ ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ថ្នាំដែលមានប្រសិទ្ធភាពអាចព្យាបាលជំងឺបានគឺមានតិចតួចបំផុត ។ ប្រជាជនភាគច្រើនមិនដែលបានទទួលការព្យាបាលជំងឺទាល់តែសោះ ។

យើងមិនដឹងថាតើប្រភេទថ្នាំអ្វីខ្លះដែលខ្មែរក្រហមកំពុងតែផលិត ។ ខ្មែរក្រហមនិយាយអំពីថ្នាំឫសឈើ មើមឈើ ហើយអះអាងថាមានប្រសិទ្ធភាពអាចព្យាបាលជំងឺបានច្រើនមុខ ។ គំនិតជ្រុលនិយមនេះបណ្តាលឲ្យប្រជាជនស្លាប់អស់ជាច្រើននាក់ ។

អ្នកផលិតឱសថ





## អ្នកផលិតឱសថ

### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ខ្មែរក្រហមអះអាងថា ដំណើរការទាំងអស់នៅក្នុងរោងចក្របង្កើតឡើងដោយស្មារតីយល់ដឹងបដិវត្តន៍របស់កសិករ ។ នៅពេលដែលយើងសួរថាតើកសិករទាំងអស់នោះធ្វើម្តេចដឹងអំពីវិធីផ្សំវត្ថុធាតុដើមនិងចំហុយថ្នាំ ខ្មែរក្រហមឆ្លើយថា មានជំនួយពី«វេជ្ជបណ្ឌិតបដិវត្ត» ។

ចុះវាមានបញ្ហាអ្វី បើគ្រាន់តែទទួលស្គាល់ថាអ្នកឯងបានប្រើប្រាស់ចំណេះដឹងរបស់បញ្ញវន្ត?

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

គំនិតរបស់ខ្មែរក្រហមដែលមិនទទួលស្គាល់វិទ្យាសាស្ត្រនិងបន្ទុបបង្អាក់ការចេះដឹងរបស់មនុស្ស គឺជាកេរ្តិ៍ដំណែលអំពី«បងធំទាំងបួន»របស់ចិន គឺការមាក់ងាយបញ្ញវន្ត ។ បញ្ញវន្តទាំងនោះត្រូវបានចាត់ទុកជាសត្រូវរបស់បដិវត្តន៍ ។

តាមពិតមេដឹកនាំខ្មែរក្រហមខ្លួនឯងគឺជាអតីតបញ្ញវន្ត ប៉ុន្តែខំប្រឹងលាក់លៀមមិនឲ្យអ្នកដទៃដឹង ។

## រោងចក្រផលិតឱសថនៅកំពង់ចាម



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

តើកុមារទាំងអស់នេះគឺជាក្មេងកំព្រាហើយត្រូវបានបដិវត្តន៍យកមកចិញ្ចឹមឬក៏ជាកុមារដែលត្រូវពង្រាត់ពីឪពុកម្តាយ?

កិច្ចការដែលកុមារទាំងនេះកំពុងតែធ្វើ (បញ្ចូលថ្នាំទៅក្នុងអំពូល) គឺជាការងារដែលមិនស័ក្តិសមចំពោះកុមារទាល់តែសោះ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

សម្លៀកបំពាក់របស់កុមារទាំងនេះដូចជាសម្លៀកបំពាក់យោធា ហើយពាក្យស្លោកនិងការឃោសនារបស់ខ្មែរក្រហមធ្វើឲ្យប្រទេសនេះមើលទៅដូចជានៅតែមានសង្គ្រាមមិនចេះចប់ ។

តាមពិតទៅការឃោសនារបស់ខ្មែរក្រហមគឺដដែលៗ ហើយការឃោសនាទាំងនេះបង្កឲ្យមានការមិនទុកចិត្តគ្នាកាន់តែខ្លាំង ដែលនេះគឺជាចំណុចសំខាន់នៅក្នុងគំនិតរបស់មេដឹកនាំខ្មែរក្រហម ។



ផ្ទះសំណាក់នៅក្រៅទីរួមខេត្តកំពង់ធំ

# នៅតាមផ្លូវឆ្ពោះទៅសៀមរាប



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

យើងមិនមានអារម្មណ៍ថាមានការគាបសង្កត់នៅទីនេះទាល់តែសោះ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើអ្នកទាំងអស់នេះជាប្រជាជនមូលដ្ឋានឬ? តើនេះជាការរៀបចំឡើងដើម្បីបំភាន់ភ្នែកយើងមែនទេ?

# ការដ្ឋានសាងសង់ទំនប់ប្រឡាយនៅតាមផ្លូវទៅទិសខាងជើង



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

នេះពិតជាជោគជ័យដ៏គួរឲ្យភ្ញាក់ផ្អើល ។ នេះគឺជាចំណុចពិសេសរបស់កម្ពុជាដែលមានតែមួយគត់ គឺចិញ្ចឹមប្រជាជនទូទាំងប្រទេសដោយមិនចាំបាច់ពឹងផ្អែកទៅលើជំនួយពីបរទេស ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

បដិវត្តន៍នេះដំណើរការឆ្ពោះទៅរកគោលដៅដ៏ធំមួយដែលប្រជាជនត្រូវតែស្តាប់បញ្ជា ហើយបញ្ជានោះទៀតសោត មិនខ្វល់អំពីជីវិតរបស់មនុស្សម្នាក់ៗ ។

គម្រោងការនោះធ្វើទៅមិនរួចទេ ។ ប្រជាជនធ្វើការងារធ្ងន់ប៉ុន្តែគ្មានអាហារគ្រប់គ្រាន់សម្រាប់បរិភោគ ។ ហេតុអ្វីក៏មិនប្រើប្រាស់គ្រឿងម៉ាស៊ីនខ្លះទៅ ដើម្បីកុំឲ្យប្រជាជនធ្វើការងារធ្ងន់ធ្ងរបែបនេះ? ខ្មែរក្រហមទទួលជំនួយពីប្រទេសចិនដែរ ហេតុអ្វីក៏មិនប្រើប្រាស់ជំនួយទាំងនោះក្នុងការសាងសង់ទំនប់ប្រឡាយបែបនេះ បែរជាបង្ខំឲ្យប្រជាជនធ្វើការងារហួសកម្លាំងទៅវិញ?

## ការដ្ឋានសាងសង់ទំនប់ប្រឡាយ





## ការដ្ឋានសាងសង់ទំនប់ប្រឡាយ

## អ្នកធ្វើការនៅក្នុងការដ្ឋានសាងសង់ទំនប់ប្រឡាយ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ប្រជាជនសប្បាយរីករាយ និងមានទឹកមុខញញឹមញញែម ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ហេតុអ្វីក៏ប្រជាជនសប្បាយរីករាយ និងមានទឹកមុខញញឹមញញែមទៅកើត? ប្រហែលជាអ្នកទាំងនោះមួយចំនួនគាំទ្របដិវត្តន៍ខ្មែរក្រហម មួយចំនួនទៀតបានទទួលផលប្រយោជន៍ខ្លះៗ ហើយមួយចំនួនទៀតគ្រាន់តែធ្វើពុតជាញញឹម ។



សមាជិកកងចល័តនៅការដ្ឋានសាងសង់ទំនប់ប្រឡាយ

# ផ្នែកមួយនៃប្រឡាយដែលជីករួច



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

គម្រោងជីកទំនប់ប្រឡាយមើលទៅមានប្រសិទ្ធភាព ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

មើលទៅដូចជាគម្រោងកសាងទំនប់ប្រឡាយគឺជាផ្នែកមួយនៃសុបិនដ៏មហិមាប៉ុន្តែក្លែងក្លាយរបស់មេដឹកនាំខ្មែរក្រហម ។



កសិដ្ឋានចិញ្ចឹមក្រពើនៅសៀមរាប

# ប្រាសាទបាយ័ន



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨និងបច្ចុប្បន្ន

សេចក្តីចម្រើនរុងរឿងបានកើតឡើងហើយក៏រលាយបាត់ទៅវិញ ។ ប្រាសាទថ្មទាំងអស់នេះតំណាងឲ្យភាពចម្រើនរុងរឿងនិងកម្លាំងញើសឈាមរបស់ប្រជាជនរាប់ពាន់នាក់ដែលបន្សល់ទុកប្រាសាទដ៏ស្កឹមស្កៃជាកេរ្តិ៍ដំណែល  ក៏ប៉ុន្តែគ្មានឈ្មោះរបស់អ្នកទាំងអស់នោះនៅក្នុងសៀវភៅប្រវត្តិសាស្ត្រទាល់តែសោះ ។



អង្គធំ : ច្រកចូលប្រាសាទបាយ័ន

អង្គធំ : ច្រកចូលប្រាសាទបាយ័ន





ប្រាសាទបាយ័ន្ត

ឆាក់រហាត់នាំទឹកបញ្ចូលស្រែ





## កម្មកររោងចក្រនៅទីក្រុងភ្នំពេញ ផលិតឧបករណ៍កសិកម្ម

### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

សេដ្ឋកិច្ចដែលបានគ្រោងទុកក៏មើលទៅដូចជាដំណើរការដែរ ។ នៅទីនេះ កម្ពុជាផ្តោតការយកចិត្តទុកដាក់ទៅលើចំណុចសំខាន់បំផុត គឺកសិកម្ម ផ្ទុយពីបដិវត្តន៍របស់ ស្តាលីន ដែលព្យាយាមអភិវឌ្ឍប្រព័ន្ធឧស្សាហកម្មឲ្យបានឆាប់រហ័សក្នុងរយៈពេលដ៏ខ្លី ។ បដិវត្តន៍កម្ពុជាក៏ជាបដិវត្តន៍ឈានមុខបើប្រៀបធៀបទៅនឹងបដិវត្តន៍របស់ ម៉ៅ នៅប្រទេសចិន ។

ត្រូវតែផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាសំខាន់!

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ផ្តោតការយកចិត្តទុកដាក់និងការរៀបគម្រោងសម្រាប់សេដ្ឋកិច្ចគឺល្អហើយ ក៏ប៉ុន្តែទាំងអស់នេះបានប្រែក្លាយប្រទេសឲ្យទៅជាជំរំប្រមូលផ្តុំដែលមានតែពលកម្មបាក់កម្លាំងនិងការបំបិទសិទ្ធិសេរីភាព ។

កម្មកររោងចក្រនៅទីក្រុងភ្នំពេញ





## កុមារធ្វើការនៅក្នុងរោងចក្រ

**ការយល់ឃើញក្នុងឆ្នាំ១៩៧៨និងពេលបច្ចុប្បន្ន**

*កុមារនេះគួរតែទៅសាលារៀនៗ*

រោងចក្រនៅទីក្រុងភ្នំពេញ



# សាលាបច្ចេកទេសនៅទីក្រុងភ្នំពេញ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

តើរូបភាពនេះពិតដែរឬទេ? ខ្មែរក្រហមនិយាយប្រាប់យើងថាការបង្រៀននៅទីនេះគឺរៀបចំឡើងដោយកសិករបដិវត្តន៍ និងគ្មានការប្រើប្រាស់គ្រូបង្រៀនពីរបបមុនទេ ។

ជាថ្មីម្តងទៀត គោលគំនិតរបស់បដិវត្តន៍ក្លែងក្លាយនេះគឺចាត់ទុកបញ្ញវន្តជាសត្រូវ ។ មិនយូរមិនឆាប់ខ្មែរក្រហមនឹងលះបង់គំនិតនេះ ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើសាលានេះមានពិតមែនឬក៏គ្រាន់តែជាការរៀបចំឲ្យយើងមើលឃើញថាមានសាលារៀន?

# សិស្សនៅសាលាបច្ចេកទេស



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨**

តើនរណាទៅជឿថាទាំងអស់នេះត្រូវបានបង្កើតឡើង ដោយមិនពឹងផ្អែកលើចំណេះដឹងពីមុនៗមក?

**ការយល់ឃើញក្នុងពេលបច្ចុប្បន្ន**

តាមមើលទៅទាំងអស់នេះសុទ្ធតែជាការកុហក ។

# គ្រូបង្រៀននៅសាលាបច្ចេកទេស



***ការយល់ឃើញក្នុងឆ្នាំ១៩៧៨និងពេលបច្ចុប្បន្ន***

*នៅសាលានេះមានសិស្សតែប៉ុន្មាននាក់ប៉ុណ្ណោះ ។ តើទាំងអស់នេះពិតឬក៏ក្លែងក្លាយ?*

## មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

មើលទៅដូចជាគ្មានអ្នកជំងឺនៅក្នុងមន្ទីរពេទ្យទាល់តែសោះ ក៏ប៉ុន្តែមើលទៅមន្ទីរពេទ្យដូចជាដំណើរការធម្មតា ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

មន្ទីរពេទ្យនេះអាចគ្រាន់តែជាការរៀបចំដើម្បីឲ្យយើងមើលតែប៉ុណ្ណោះ ។ មិនប្រាកដដែរ!

# មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨និងពេលបច្ចុប្បន្ន**

*នៅឯណាអ្នកជំងឺ? តើនេះពិតជាមន្ទីរពេទ្យមែនឬ? មន្ទីរពេទ្យនេះសម្រាប់អ្នកណា?*

## មន្ទីរពេទ្យនៅទីក្រុងភ្នំពេញ



## របាំបដិវត្តនៅរោងមហោស្រពទីក្រុងភ្នំពេញ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

សិល្បៈនេះក៏ត្រូវបានសម្តែងទទួលគណៈប្រតិភូសិល្បៈមកពីប្រទេសរ៉ូម៉ានីដែរ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

នេះគឺជារបាំប្រពៃណីដែលលើកសរសើរបដិវត្តន៍ ។ ខ្ញុំឆ្ងល់ថា តើពេលនោះ ឡូរ៉ង់ ពិច ដែលជាជនជាតិបារាំងតែម្នាក់គត់ដែលរស់នៅក្នុងប្រទេសកម្ពុជាក្នុងរបបនោះ ពិតជាកំពុងតែស្ថិតនៅពីក្រោយឆាក ។ បើគាត់ពិតជានៅទីនោះមែន តើគាត់មានអារម្មណ៍ដូចម្តេចនៅពេលដែលឃើញគណៈប្រតិភូយើងប៉ុន្តែមិនអាចទាក់ទងបាន?

# សិល្បៈបដិវត្តនៅរោងមហោស្រពទីក្រុងភ្នំពេញ





## សិល្បៈបដិវត្តនៅរោងមហោស្រពទីក្រុងភ្នំពេញ

បុរសម្នាក់នេះដេញឧបករណ៍ម្យ៉ាងដែលខ្ញុំយល់ថា ជាឧបករណ៍ភ្លេងប្រពៃណីខ្មែរ ។ ដូច្នេះមានន័យថា ខ្មែរក្រហមក៏ទទួលស្គាល់វប្បធម៌ពីសង្គមចាស់ដែរ ។

# សហករណ៍តម្បាញនៅខាងក្រុងភ្នំពេញ



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ខ្ញុំសួរខ្មែរក្រហមតើកម្មករនៅទីនេះបានអាហារមកពីណាដើម្បីបរិភោគបើនៅទូទាំងប្រទេសគ្មានក្រដាសប្រាក់និងគ្មានការដូរញដូរ ។ ខ្មែរក្រហមឆ្លើយថា ខាងសហករណ៍ផ្សេងៗដឹកផលិតផល ស្បៀងអាហារដែលលើសពីតម្រូវការមកដោះដូរយកសម្លៀកបំពាក់ ។ បើដូច្នេះមានន័យថាពិតជាមាននរណាម្នាក់ជាអ្នកសម្រេចការដោះដូរនេះ ។

បើធ្វើបែបនេះប្រាកដជាមានភាពស្មុគស្មាញ នៅពេលដែលសេដ្ឋកិច្ចរីកចម្រើនជាងនេះ ។ ដល់ពេលនោះខ្មែរក្រហមពិតជាត្រូវការប្រើប្រាស់ក្រដាសប្រាក់ ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ចំណុចដែលគួរឲ្យកត់សម្គាល់របស់បក្សកុម្មុយនិស្តកម្ពុជាដែលចង់បោះជំហានឲ្យបានឆាប់រហ័ស គឺថាចង់ធ្វើជាបដិវត្តន៍គំរូឈានមុខមុនបដិវត្តន៍របស់ចិន កូរ៉េ អាល់បានី និងបដិវត្តន៍ផ្សេងៗទៀត ។ ខ្មែរក្រហមមិនបានយកចិត្តទុកដាក់ដល់ប្រជាជនហើយបង្កើតបដិវត្តន៍មួយដែលមានតែរូបភាព ប៉ុន្តែគ្មានការពិចារណាដល់ភាពជាមនុស្ស ។



កម្មករតម្បាញ

# ផែកប៉ាល់នៅកំពង់សោម




## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

នេះបង្ហាញឲ្យឃើញថាកម្ពុជាមិនមែនឯកោទេ ។ មានការនាំទំនិញចេញ-ចូលក្នុងនិងក្រៅប្រទេស គ្រាន់តែក្នុងទ្រង់ទ្រាយតូច ។

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ខ្មែរក្រហមនាំចូលទំនិញពីចិននិងកូរ៉េ ជាពិសេសប្រេងឥន្ធនៈ ក្នុងបរិមាណច្រើនជាងបរិមាណដែលមេដឹកនាំខ្មែរក្រហមបានបញ្ចេញឲ្យដឹង ។

គោលនយោបាយម្ចាស់ការខ្លួនទីពឹងខ្លួនមិនប្រាកដថាសុទ្ធតែត្រូវបានអនុវត្តទាំងស្រុងទេ ។ អ្វីដែលជាការពិតនោះគឺថាការនាំចេញមួយចំនួនមានតម្លៃស្មើនឹងទុក្ខវេទនារបស់ប្រជាជន ជាពិសេសការនាំចេញអង្ករក្នុងខណៈដែលប្រជាជនកំពុងតែស្លាប់ដោយគ្មានអាហារបរិភោគ ។



សំឡីគសម្រាប់នាំចេញ

## ការផលិតទូកនៅក្រុងកំពង់សោម





ការផលិតទូក

## នាវារបស់យោធាខ្មែរក្រហម



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨ និងពេលបច្ចុប្បន្ន**

នាវាទាំងនេះនិងរថយន្តពិតជាត្រូវការប្រេងឥន្ធនៈ ។ ខ្មែរក្រហមពិតជានាំចូលប្រេងឥន្ធនៈច្រើនជាងចំនួនដែលបាននិយាយ ។

## ទូកនេសាទ



***ការយល់ឃើញក្នុងឆ្នាំ១៩៧៨***

*តើខ្មែរក្រហមប្រើប្រាស់ទូកទាំងនេះឬក៏ទុកចោល?*

## កុមារនៅលើនាវា



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

កុមារទាំងនេះគួរតែទៅសាលារៀន ក៏ប៉ុន្តែប្រសិនបើកុមារទាំងនេះជាក្មេងកំព្រាវិញ រស់នៅទីនេះប្រសើរជាងដើរអនាថាតាមដងផ្លូវ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

បើទោះបីជាកុមារទាំងនេះជាក្មេងកំព្រាក៏គួរតែទៅសាលារៀនដែរ ។ តើនេះជាក្មេងកំព្រាឬក៏មិនមែន?



មធ្យោបាយដឹកជញ្ជូននៅភាគអាគ្នេយ៍
នៃប្រទេស

## ទីប្រជុំជនកំពត



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨**

តើប្រជាជននៅទីប្រជុំជននេះត្រូវជម្លៀសចេញអស់ដែរឬ?

**ការយល់ឃើញក្នុងពេលបច្ចុប្បន្ន**

មើលតែរូបភាពនេះទៅដឹងហើយ ។

# សហករណ៍នៅភាគអាគ្នេយ៍នៃប្រទេស



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ខ្មែរក្រហមអះអាងថា សហករណ៍នេះត្រូវផ្លាស់ទីកន្លែងមកពីតំបន់ព្រំដែនវៀតណាម ។

ខ្ញុំយល់ថាខ្មែរក្រហមនាំយើងមកមើលសហករណ៍នេះ ពីព្រោះវាដំណើរការបានល្អ ។



ប្រធានសហករណ៍

## កុមារនៅសហករណ៍



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨**

កុមារទាំងនេះមើលទៅដូចជាមិនអីទេ ។

## ផ្ទះបាយសហករណ៍



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨**

មើលទៅដូចជាមានម្ហូបអាហារគ្រប់គ្រាន់ ។

**ការយល់ឃើញក្នុងពេលបច្ចុប្បន្ន**

នេះគឺជាផ្ទះបាយសហករណ៍ដែលជ្រើសរើសសម្រាប់បង្ហាញភ្ញៀវបរទេស ។



## រោងជាងសហករណ៍

ផលិតជប





កុមារីនៅសហករណ៍

កុមារីនិងគ្រូបង្រៀននៅសហករណ៍





មណ្ឌលកុមារ

## កុមារនៅភាគអគ្នេយ៍នៃប្រទេស



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨**

កុមារទាំងអស់នេះមើលទៅដូចជាមិនអីទេ ។

**ការយល់ឃើញក្នុងពេលបច្ចុប្បន្ន**

តើកុមារទាំងនេះជាកូនរបស់អ្នកមូលដ្ឋានឬ?



## ការយល់ឃើញក្នុងឆ្នាំ១៩៧៨

រថយន្តរបស់យើងឆ្លងកាត់ទីនេះ ហើយក៏ឈប់មួយភ្លែត ។ ខ្មែរក្រហមអះអាងថា ក្រុមគ្រួសារនីមួយៗគួរតែមានផ្ទះថ្មីមួយ ។ អស្ចារ្យ!

## ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើនេះជាការរៀបចំបន្ទំភ្នែកមែនទេ? បុរសម្នាក់ដែលកំពុងធ្វើការនៅទីនេះនិយាយភាសាបារាំង ខ្ញុំគិតថាគាត់អាចត្រូវខ្មែរក្រហមសម្លាប់ ។

## ផ្ទះគំរូ



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ប្រសិនបើគ្រប់គ្រួសារមានផ្ទះធំបែបនេះគឺគ្រប់គ្រាន់ហើយសម្រាប់ប្រទេសដែលក្រីក្រ ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

តើផ្ទះនេះជារបស់អ្នកមានទ្រព្យសម្បត្តិគ្រាន់បើ ឧទាហរណ៍ដូចជាមានកង់ជិះជាដើម?

# ថ្នាក់រៀន



**ការយល់ឃើញក្នុងឆ្នាំ១៩៧៨**

នេះគឺជាសក្ខីភាពមួយទៀតដែលបញ្ជាក់ថា ការនិយាយអាក្រក់អំពីកម្ពុជាគឺមិនពិត ។ កម្ពុជាពិតជាមានសាលារៀន ។

**ការយល់ឃើញក្នុងពេលបច្ចុប្បន្ន**

កុមារទាំងនេះច្បាស់ជាកូនរបស់កម្មាភិបាលខ្មែរក្រហមឬប្រជាជនមូលដ្ឋានដែលអង្គការមានទំនុកចិត្ត ។

ថ្នាក់រៀន





សាលារៀន

## រថក្រោះរបស់វៀតណាម



### ការយល់ឃើញក្នុងឆ្នាំ១៩៧៨

ខ្មែរក្រហមអះអាងអំពីជ័យជម្នះដ៏ធំធេងមហិមា ។

### ការយល់ឃើញដែលត្រូវហាមឃាត់កាលពីពេលនោះ

ផ្នែកមួយនៃគោលនយោបាយរបស់ខ្មែរក្រហមគឺប្រកាន់ពូជសាសន៍ ហើយផ្នែកផ្សេងទៀតគឺសង្ស័យហួសហេតុនិងខុស (ឧទាហរណ៍ សៀវភៅខ្មៅដែលបោះពុម្ពក្នុងខែធ្នូ ឆ្នាំ១៩៧៨) ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ការឃោសនាបែបនេះគឺជាផ្នែកមួយនៃគោលនយោបាយរបស់ខ្មែរក្រហមដែលយើងពិបាកយល់ ។ វាច្បាស់ណាស់ថាខ្មែរក្រហមបានបន្តរឿងដើម្បីវាយប្រហារវៀតណាមនិងសម្លាប់ប្រជាជននៅក្នុងទឹកដីវៀតណាម ។

សំណួរសួរថា ហេតុអ្វី? មួយផ្នែកប្រហែលជាខ្មែរក្រហមចង់ប្រមូលផ្ដុំប្រជាជនប្រឆាំងនឹងសត្រូវរួម មួយផ្នែកទៀតប្រហែលជាខ្មែរក្រហមចង់ដណ្ដើមយកទឹកដីកម្ពុជាក្រោមមកវិញ ។ មានការប្រកាន់ពូជសាសន៍នៅក្នុងគោលនយោបាយរបស់ខ្មែរក្រហម ។



## បុរសនេះជាជនភៀសខ្លួនពីប្រទេសវៀតណាម (កម្ពុជាក្រោម)

### ការយល់ឃើញក្នុងពី១៩៧៨

ខ្មែរក្រហមប្រាប់យើងថាប្រជាជនដែលរស់នៅក្នុងជំរំនេះគឺជាជនជាតិកម្ពុជាក្រោមដែលត្រូវវៀតណាមធ្វើទុក្ខបុកម្នេញ ហើយភៀសខ្លួនមកពីប្រទេសវៀតណាម ។

### ការយល់ឃើញក្នុងពេលបច្ចុប្បន្ន

ពិបាកនឹងរកឲ្យឃើញថាតើនេះជាការពិតឬមិនពិតពីព្រោះយើងមិនចេះភាសាខ្មែរ ។ តើយើងត្រូវគេបោកប្រាស់ឬ? អាចដែរ!

# ដំណើរទស្សនកិច្ចនៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលខ្មែរក្រហមកាន់អំណាច



ការឈប់សំចតនៅតាមផ្លូវដើម្បីឲ្យគណៈប្រតិភូថតរូប និងថតវីដេអូ

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៨ យន្តហោះពីទីក្រុងប៉េកាំងប្រទេសចិនបានចុះចតនៅព្រលានយន្តហោះពោធិ៍ចិនតុង ។ ខ្ញុំជាសមាជិកម្នាក់ក្នុងចំណោមសមាជិកបួននាក់នៃគណៈប្រតិភូស៊ុយអែដដែលត្រូវបានអញ្ជើញមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ។ នៅក្រោមរបបខ្មែរក្រហម មិនមានជនបរទេសច្រើនទេដែលបានទទួលការអនុញ្ញាតធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ។ អ្នកដែលបានចូលមកគឺជាអ្នកការទូត សមាគមមិត្តភាព ឬគណៈប្រតិភូដែលគាំទ្រមនោគមន៍វិជ្ជា ម៉ៅនិយម ។ ខ្ញុំយល់ថា ខ្មែរក្រហមសម្រេចចិត្តថាខ្លួនត្រូវតែលាងជម្រះពាក្យចចាមអារ៉ាមអំពីការកាប់សម្លាប់ ការធ្វើទារុណកម្ម និងការបំភិតបំភ័យ ដែលខ្លួនប្រឈមមុខចាប់តាំងពីឡើងកាន់អំណាចនៅខែមេសា ឆ្នាំ១៩៧៥ ។ ក៏ប៉ុន្តែខ្មែរក្រហមនៅតែបារម្ភអំពីការគ្រប់គ្រងស្ថានការណ៍នៅចំពោះមុខ និងចង់ឲ្យប្រាកដក្នុងចិត្តថាភ្ញៀវដែលខ្លួនអញ្ជើញមកនឹងមិនបង្កបញ្ហា ។ នៅពេលជិតដល់ចុងបញ្ចប់នៃរបបរបស់ខ្លួន ខ្មែរក្រហមអញ្ជើញអ្នកកាសែតឯករាជ្យពីរ-បីនាក់ទៅកម្ពុជា ។

មុនពេលចេញដំណើរ យើងបានពិភាក្សាគ្នាអំពីបញ្ហាជាច្រើន ។ យើងមិនចង់ឲ្យខ្មែរក្រហមប្រើប្រាស់យើងជាផ្នែកមួយនៃគោលនយោបាយប្រល័យពូជសាសន៍នោះទេ ។ ដូច្នេះហើយ យើងមានបំណងដាក់ចិត្តថាពាក្យចចាមអារ៉ាមទាំងអស់គឺមិនពិត ។ យើងយល់ស្របជាមួយគ្នាថា ប្រហែលជាមានការរំលោភសិទ្ធិមនុស្សនិងការគាបសង្កត់ ក៏ប៉ុន្តែយើងលើកហេតុផលថា នៅគ្រប់បដិវត្តន៍តែងតែមានការរំលោភសិទ្ធិមនុស្សខ្លះៗ ក៏ប៉ុន្តែមិនយូរប៉ុន្មានវានឹងបាត់ទៅវិញ ។ គ្មានបដិវត្តន៍ណាមួយល្អឥតខ្ចោះនោះទេ ហើយយើងត្រៀមខ្លួនទៅមើលបដិវត្តន៍មួយដែលកំពុងតែអភិវឌ្ឍ ។ យើងមិនបានត្រៀមសម្តីឬសកម្មភាព ហើយយើងមិនដឹងថាត្រូវបញ្ចេញប្រតិកម្មដូចម្តេចក្នុងករណីដែលពាក្យចចាមអារ៉ាមមួយចំនួនអំពីការកាប់សម្លាប់និងគាបសង្កត់នៅក្នុងប្រទេសកម្ពុជាគឺជាការពិត ។

យើងបានឃើញតែអ្វីដែលខ្មែរក្រហមចង់ឲ្យយើងឃើញ ។ ដោយមើលឃើញដូច្នោះ យើងបានព្យាយាមរកមើលអ្វីដែលខ្មែរក្រហមលាក់បាំងនិងមិនចង់ឲ្យយើងឃើញ ។ យើងស្នាក់នៅទីក្រុងភ្នំពេញ ហើយមិនដែលបានទទួលការអនុញ្ញាតឲ្យស្នាក់នៅសហករណ៍ទាល់តែសោះ ។ នៅក្នុងទីក្រុងភ្នំពេញ យើងអាចដើរទៅណាមកណាបានដោយសេរី ក៏ប៉ុន្តែរាល់លើកដែលយើងចេញដើរតែងតែមានកងសន្តិសុខដើរតាមយើងជាប់ជានិច្ច ។ ខ្មែរក្រហមយកលេសថាទាហានទាំងនោះតាមការពារសុវត្ថិភាពរបស់យើង ក៏ប៉ុន្តែតាមខ្ញុំយល់ទាហានទាំងនោះក៏អាចរាយការណ៍ទៅថ្នាក់លើអំពីសកម្មភាពរបស់យើងបានដែរ ។ មានតែម្តងគត់ដែលយើងត្រូវឃាត់ដំណើរគឺនៅយប់ទីមួយដែលយើងស្នាក់នៅទីក្រុងភ្នំពេញ ស្ត្រីពីរនាក់នៅក្នុងក្រុមរបស់យើងចេញដើរបានតែពីរបីនាទីក៏ត្រូវខ្មែរក្រហមស្កាត់ផ្លូវនិងបញ្ឈប់ដំណើរ ។ យើងបានរអ៊ូរទាំអំពីរឿងនោះ ហើយតាំងពីពេលនោះមកគ្មាននរណាម្នាក់បញ្ឈប់ដំណើររបស់យើងទៀតទេ ។

ពេលខ្លះយើងសុំឲ្យរថយន្តឈប់សំចតតាមផ្លូវ ដើម្បីថតវីដេអូនិងដើម្បីមើលអ្វីៗដែលមិនមែនជាការរៀបចំរបស់ខ្មែរក្រហមសម្រាប់បង្ហាញយើង ។ ខ្មែរក្រហមអនុញ្ញាតតាមសំណើរបស់យើង ។ យើងដើរពាសពេញទីក្រុង ក៏ប៉ុន្តែយើងមិនអាចធ្វើអ្វីលើសពីនេះបានទេ ។ ក្នុងរយៈពេល១៨ថ្ងៃ ខ្មែរក្រហមនាំយើងដើរមើលកន្លែងជាច្រើន ។ យើងពឹងផ្អែកទាំងស្រុងទៅលើមគ្គុទ្ទេសក៍របស់យើង ។ នេះជាមូលហេតុមួយដែលខ្ញុំគិតថាដំណើរទស្សនកិច្ចនោះមិនគួរកើតមាន

ទាល់តែសោះ ។ វាគឺជាផ្នែកមួយនៃការឃោសនានយោបាយរបស់ខ្មែរក្រហម ។

តើយើងអាចជឿអ្វីដែលខ្មែរក្រហមនិយាយប្រាប់យើងបានដែរឬទេ? ខ្ញុំអាចឆ្លើយបានតែសម្រាប់ខ្លួនឯង គឺថាមានរឿងមួយចំនួនខ្ញុំមិនដែលជឿទាល់តែសោះ ។ យើងមិនជឿថាខ្មែរក្រហមឆ្លើយត្រង់ទៅនឹងសំណួររបស់យើងជុំវិញពាក្យចចាមអារ៉ាមទាំងអម្បាលម៉ានអំពីការកាប់សម្លាប់ចាប់តាំងពីខ្មែរក្រហមឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ នៅពេលដែលយើងសួរអំពីប្រព័ន្ធតុលាការ ចម្លើយរបស់ខ្មែរក្រហមគឺមិនគួរជាទីពេញចិត្តទាល់តែសោះ ។ ខ្មែរក្រហមនិយាយថា ប្រព័ន្ធច្បាប់ទាំងនោះគឺមិនចាំបាច់មានទាល់តែសោះ បញ្ហាទាំងអស់ត្រូវដោះស្រាយដោយគណៈកម្មការភូមិ គឺប្រជាជន ។ ចាប់ពីពេលនោះមកខ្ញុំមើលឃើញថា កង្វះខាតប្រព័ន្ធច្បាប់នឹងបង្កឲ្យការរំលោភសិទ្ធិមនុស្សរេះតែបន្តកើតមាន ។ ខ្ញុំចាត់ទុកកង្វះខាតនេះថា ជាភាពក្មេងខ្ចីនៃបដិវត្តន៍ខ្មែរក្រហម និងកង្វះខាតប្រជាធិបតេយ្យនៅប្រទេសកម្ពុជា ។

យើងសួរសំណួរជាច្រើនអំពីអ្វីដែលយើងបានឃើញ ។ មានរឿងមួយចំនួនដែលខ្មែរក្រហមបង្ហាញយើង ហើយដែលខ្ញុំគិតថាវាពិបាកក្នុងការគ្រប់គ្រង ។ តើមន្ទីរពេទ្យនៅក្នុងទីក្រុងភ្នំពេញដែលយើងបានទៅមើលស្ថិតនៅក្នុងស្ថានភាពពិតឬក៏គ្រាន់តែជាការរៀបចំបង្ហាញយើង? តើរឿងរ៉ាវដែលជនភៀសខ្លួនមកពីវៀតណាមនិយាយប្រាប់យើងជាការពិតឬ? គ្មានវិធីដែលយើងអាចដឹងបានទេ ។ យើងរេះតែបន្តសួរសំណួរ ហើយពេលខ្លះយើងក៏ទទួលបានចម្លើយគួរជាទីពេញចិត្តពេលខ្លះទៀតយើងទទួលបានចម្លើយដែលខ្ញុំចាត់ទុកថាគ្រាន់តែជាការឃោសនានយោបាយប៉ុណ្ណោះ ។

កាលនោះ មានរឿងមួយចំនួនធ្វើឲ្យខ្ញុំមិនសប្បាយចិត្ត ។ នៅការដ្ឋានជីកប្រឡាយមួយ ខ្ញុំសុំជួបនិយាយជាមួយនរណាម្នាក់ក៏បានដែលធ្លាប់រស់នៅទីក្រុងពីមុន ។ ចម្លើយដែលខ្ញុំទទួលបានគឺថាទាំងអស់គ្នារវល់ធ្វើការងារបម្រើបដិវត្តន៍គ្មានពេលនិយាយជាមួយខ្ញុំទេ ។ ខ្ញុំមិនជឿទាល់តែសោះ ។ ខ្ញុំមិនចង់ជឿថាអ្នកទីក្រុងជាច្រើនត្រូវសម្លាប់ទេ ក៏ប៉ុន្តែខ្ញុំមានការមន្ទិលសង្ស័យនៅក្នុងចិត្ត ។

ខ្ញុំក៏មិនយល់ស្របជាមួយមគ្គុទ្ទេសក៍របស់យើងឈ្មោះ សុក រីម ដែលនិយាយអំពី«មនុស្សថ្មី» និង«អំណាចផ្តាច់មុខរបស់បក្ស» ។ ខ្ញុំយល់ថា គាត់នៅក្មេងខ្ចីខាងផ្នែកចំណេះដឹងអំពីការផ្លាស់ប្តូររបស់បដិវត្តន៍ ហើយគាត់យល់ខុសអំពីមនោគមន៍វិជ្ជាម៉ាក្ស ។

បើដូច្នោះ ហេតុអ្វីក៏នៅទីបំផុតយើងនៅតែជឿនិងគាំទ្ររបបខ្មែរក្រហម? ខ្ញុំយល់ថា ចំណុចសំខាន់គឺយើងចង់ជឿ ។ យើងធ្លាប់បានធ្វើការងារក្នុងចលនាប្រឆាំងនឹងសង្គ្រាមអាមេរិកនៅវៀតណាម ឡាវ និងកម្ពុជា ។ នៅពេលដែលការគាំទ្ររបស់ពិភពលោកត្រូវបែងចែកជាពីររវាងកុម្មុយនីស្តវៀតណាម និងកុម្មុយនីស្តកម្ពុជា យើងជ្រើសរើសគាំទ្រកម្ពុជា ។ យើងបានធ្វើការងារជាច្រើនឆ្នាំ ដើម្បីគាំទ្រខ្មែរក្រហម ។ តើយើងសម្រេចចិត្តខុសមែនទេ? ខ្ញុំទទួលស្គាល់ថាបដិវត្តន៍កម្ពុជាមានកំហុសមួយចំនួន ក៏ប៉ុន្តែ នៅលើលោកនេះគ្មានបដិវត្តន៍ ដែលឥតខ្ចោះនោះទេ ហើយខ្ញុំត្រូវតែប្រកាន់យកគោលជំហរមួយ ។ ខ្ញុំបានប្រាប់ខ្លួនឯងថា បដិវត្តន៍កម្ពុជាមានចំណុចល្អច្រើនជាងចំណុចអាក្រក់ ។ ខ្ញុំកំពុងតែពាក់វ៉ែនតារបស់ ម៉ៅ ។

មូលហេតុផ្សេងទៀតដែលធ្វើឲ្យយើងជឿបដិវត្តន៍គឺថាតាមអ្វីដែលយើងមើលឃើញ ពាក្យចចាមអារ៉ាមមិនល្អអំពីស្ថានភាពនៅកម្ពុជាគឺមិនមែនជាការពិត ។ យើងជួបអ្នកពាក់វ៉ែនតា ខណៈដែលពាក្យចចាមអារ៉ាមនិយាយថា អ្នកពាក់វ៉ែនតាត្រូវសម្លាប់ចោលអស់ទៅហើយ ។ យើងបានជួបមនុស្សដែលតាមពាក្យចចាមអារ៉ាមនិយាយថា គាត់ត្រូវសម្លាប់ ប៉ុន្តែតាមពិតគាត់នៅរស់ ។ គ្រប់ទីកន្លែងដែលយើងទៅដល់ យើងមិនឃើញមានទុរ្ភិក្សទាល់តែសោះ ។ ដូច្នេះ បើពាក្យចចាមអារ៉ាមមួយចំនួនមិនមែនជាការពិតទៅហើយ តើចាំបាច់អ្វីដែលយើងជឿពាក្យចចាមអារ៉ាមផ្សេងទៀត?

យើងគួរតែគិតថា ពាក្យចចាមអារ៉ាមទាំងនោះអាចជាការពិត មិនដូចជាអ្វីដែលយើងបានឃើញ ។ ក្នុងអំឡុងដំណើរទស្សនកិច្ច យើងកាន់តែមានសុទិដ្ឋិនិយមខ្លាំងឡើង ហើយខ្ញុំជឿថានេះគឺជាសភាពធម្មតានៃចិត្តសាស្ត្ររបស់មនុស្ស ។ ចុះប្រសិនបើយើងត្រឡប់មកពីប្រទេសកម្ពុជាវិញហើយនិយាយថាពាក្យចចាមអារ៉ាមជាច្រើនអំពីប្រទេសកម្ពុជាគឺជាការពិត តើនឹងមានរឿងអ្វីកើតឡើង? ខ្ញុំយល់ថាយើងមិនទាន់បានត្រៀមខ្លួនសម្រាប់ហេតុការណ៍បែបនោះទេ ។ យើងមិនបានលាក់បាំងអ្វីដែលយើងបានឃើញនោះទេ ។ ខ្ញុំនៅចាំថា ខ្ញុំមានអារម្មណ៍ទើសទាល់យ៉ាងខ្លាំងនៅពេលដែលខ្មែរក្រហមស្នើសុំឲ្យខ្ញុំបញ្ចេញយោបល់ខ្លះអំពីដំណើរទស្សនកិច្ចរបស់យើង ដើម្បីចាក់ផ្សាយនៅស្ថានីយវិទ្យុនៅរដ្ឋធានីភ្នំពេញ ។ ខ្ញុំមិនចង់និយាយបែបឃោសនានយោបាយទេ បើទោះជាខ្ញុំគាំទ្ររបបខ្មែរក្រហមក៏ដោយ ។ ខ្ញុំនិយាយពីរ-បីម៉ាត់អំពីអ្វីដែលខ្ញុំយល់ថាខ្ញុំគាំទ្រ ហើយមិននិយាយអំពីចំណុចផ្សេងទៀត ។ ខ្ញុំមិនប្រាកដថាតើបទសម្ភាសន៍នោះត្រូវបានចាក់ផ្សាយឬអត់ទេ ក៏ប៉ុន្តែខ្ញុំនៅតែចងចាំអារម្មណ៍ទើសទាល់នៅពេលនោះ ។ ប្រហែលជាអារម្មណ៍ទើសទាល់នោះគឺជាមូលហេតុដែលនាំឲ្យខ្ញុំចាកចេញពីចលនាគាំទ្រខ្មែរក្រហមនៅពាក់កណ្តាលឆ្នាំ១៩៧៩ ហើយទទួលស្គាល់ជាចំហថាយើងបានយល់ខុសតាំងពីដើមទីមក ។

ក៏ប៉ុន្តែនៅពាក់កណ្តាលចុងឆ្នាំ១៩៧៨ ខ្ញុំនៅតែជឿជាក់ថា កម្ពុជាប្រជាធិបតេយ្យនៅតែមានតម្លៃដែលគួរតែទទួលបានការគាំទ្រនិងសាមគ្គីភាព ។

មានមេរៀនមួយចំនួនយើងគួរតែរៀនសូត្រ ។

# ជួបជាមួយ ប៉ុល ពត និង អៀង សារី



ប៉ុល ពត និង ហ្គុនណា

នៅពេលដែលយើងទៅដល់ប្រទេសកម្ពុជា យើងបាន លើកសំណើមួយចំនួនលើសពីកាលវិភាគដែលបានរៀបចំ ។ យើងសុំសម្រាកនៅសហករណ៍ពីរបុីយប់ មិនមែនគ្រាន់តែ ទៅមើលពីរ-បីម៉ោងទេ ។ ខ្មែរក្រហមបដិសេធ ។ យើងសុំ សម្ភាសន៍ ខៀវ ប៉ុណ្ណារី ប្រពន្ធរបស់ ប៉ុល ពត និងជាប្រធាន សមាគមនារី ។ ពេលខ្លះខ្ញុំសង្ស័យថាសមាគមទាំងប៉ុន្មាន ដែលខ្មែរក្រហមបាននិយាយប្រាប់យើងនោះ មិនមានរូបរាង ពិតប្រាកដទេ ។ កាលនោះយើងមិនដឹងសោះថា ខៀវ ប៉ុណ្ណារី មានជំងឺធ្ងន់ធ្ងរ ។ ខ្មែរក្រហមមិនអនុញ្ញាតឲ្យយើងជួបគាត់ ។ យើងក៏បានសុំសម្ភាសន៍ ប៉ុល ពត ហើយមិនបានទទួល ចម្លើយភ្លាមៗទេ ។ ខ្មែរក្រហមប្រាប់យើងឲ្យផ្ញើសំណួរទៅ មុន ។ យើងស៊ាំនឹងទម្លាប់បែបនេះទៅហើយ ពីព្រោះកុម្មុយ និស្តវៀតណាមនិងចិនក៏អនុវត្តដូចគ្នាដែរ ។ បណ្តាមេដឹកនាំ កុម្មុយនីស្តទាំងនោះចង់ត្រៀមចម្លើយទុកជាមុន និងមិនចង់ ជាប់កុននិយាយអ្វីដែលមិនគួរនិយាយ ។

ពីរ-បីថ្ងៃក្រោយមក ខណៈពេលដែលស្ត្រីពីរនាក់នៅ ក្នុងក្រុមរបស់យើងចេញដើរលេងនៅក្នុងទីក្រុង រថយន្តហ្ស៊ីប មួយមកដល់ដោយមានមគ្គុទ្ទេសក៍របស់យើងនៅក្នុងនោះ ។ មគ្គុទ្ទេសក៍ប្រាប់យើងឲ្យរៀបចំខ្លួនដើម្បីទៅជួប ប៉ុល ពត ក្នុងរយៈពេលពីរ-បីម៉ោងខាងមុខ ។ យើងនិយាយថា ស្ត្រី ពីរនាក់ទៀតមិននៅផ្ទះទេ ប៉ុន្តែគាត់ប្រាប់យើងកុំឲ្យបារម្ភ ។ មួយនាទីក្រោយមក ខ្មែរក្រហមដឹកស្ត្រីទាំងពីរនាក់មកដល់ផ្ទះ វិញ ។ ស្ត្រីទាំងពីរមិនយល់ទាល់តែសោះថាហេតុអ្វីក៏គាត់ ត្រូវហៅឡើងឡានដឹកត្រឡប់មកផ្ទះវិញ ពីព្រោះអ្នកបើក ឡាននិងកងសន្តិសុខខ្មែរក្រហមនិយាយតែភាសាខ្មែរ ។

រថយន្តដឹកយើងទៅវិមានប្រធានាធិបតី ។ បទសម្ភាសន៍ ចាប់ផ្តើមដោយ ប៉ុល ពត អានចម្លើយដែលនៅលើក្រដាស ឆ្លើយតបទៅនឹងសំណួរដែលយើងបានផ្ញើឲ្យ ។ គាត់មាន ឫកពាផ្លូវការជាទីបំផុត ប៉ុន្តែចម្លើយរបស់គាត់គ្មានអ្វីថ្មី ទាល់តែសោះ ។ គាត់ឆ្លៀតពេលនិយាយអំពី«ភ្នាក់ងារ» នៅក្នុងប្រទេសកម្ពុជាដែលបំផ្លិចបំផ្លាញបដិវត្តន៍ ។ យើង គាត់យល់ថាគាត់និយាយអំពីវៀតណាម ក៏ប៉ុន្តែពេលដែល គាត់បន្តនិយាយមិនល្អប្រឆាំងនឹងកម្មាភិបាលនៅក្នុងជួរបក្ស ខ្ញុំយល់ថានោះគឺជាសញ្ញានៃការមិនទុកចិត្តគ្នា ។ រដ្ឋមន្ត្រី ក្រសួងការបរទេស អៀង សារី ក៏មានវត្តមាននៅក្នុងអង្គ ប្រជុំនោះដែរ ប៉ុន្តែគាត់មិនបញ្ចេញយោបល់ឬកាត់ប្រសាសន៍ របស់ ប៉ុល ពត ទេ ។ ប៉ុល ពត និយាយជាភាសាខ្មែរ ហើយ អ្នកបកប្រែបកទៅជាភាសាបារាំង ។ យើងសួរគាត់អំពីពាក្យ ចចាមអារ៉ាមទាំងឡាយគាត់បដិសេធចោលទាំងអស់ ។

បន្ទាប់ពីបទសម្ភាសន៍ជាផ្លូវការដែលគណៈប្រតិភូ យើងបានថតសម្រាប់ចាក់ផ្សាយនៅទូរទស្សន៍ស៊ុយអែដ យើងត្រូវបានអញ្ជើញទៅទទួលទានអាហារពេលល្ងាចនៅ ក្នុងបន្ទប់ជាប់នោះ ។ តាមដែលខ្ញុំចាំ ម្ហូបដែលយើងទទួលទាន គ្រាំ គ្រី និងបាយ ។ ក្នុងពេលទទួលទានអាហារ យើងអាច និយាយដោយសេរីនិងចំហជាងមុន ហើយ អៀង សារី ក៏ចូលរួមក្នុងកិច្ចសន្ទនាដែរ ។ កិច្ចសន្ទនាគឺអំពីការឃោសនា នយោបាយរបស់ចក្រពត្តិប្រឆាំងនឹងខ្មែរក្រហម និងអំពី មូលហេតុដែលនាំឲ្យបដិវត្តន៍កម្ពុជាខុសប្លែកពីបដិវត្តន៍ដទៃ ។ ប៉ុល ពត នៅតែថ្លែងសុន្ទរកថាច្រើនជាងបញ្ចេញយោបល់ របស់គាត់ ។ ត្រង់នេះធ្វើឲ្យគាត់គ្មានអ្វីខុសប្លែកអំពីមេដឹកនាំ

កុម្មុយនីស្តផ្សេងទៀតដែលខ្ញុំធ្លាប់បានជួបទេ គឺរបៀបតែមួយ ។ នៅអំឡុងពេលបាយ ដោយធុញទ្រាន់នឹងស្តាប់ការបកប្រែភាសាបារាំងដែលគាត់ខ្លួនឯងក៏ចេះដែរនោះ ប៉ុល ពត ក៏សុំឲ្យបញ្ឈប់ការបកប្រែ ក៏ប៉ុន្តែគាត់នៅតែឆ្លើយជាភាសាខ្មែរ ទោះជាគាត់អាចនិយាយភាសាបារាំងបានក៏ដោយ ។

ចន្លោះពេលនោះ ខ្ញុំទៅបន្ទប់ទឹកជាមួយ អៀង សារី ។ ពេលដែលយើងនៅតែពីរនាក់ អៀង សារី និយាយភាសាបារាំង ។ គាត់ប្រាប់ខ្ញុំថាគាត់បានទទួលសំណើពីស្ថានីយទូរទស្សន៍លេខ២របស់ស៊ុយអែដ សុំមកធ្វើទស្សនកិច្ចនិងថតភាពយន្តឯកសារនៅប្រទេសកម្ពុជា ។ គាត់សួរខ្ញុំថាតើគាត់គួរអនុញ្ញាតដែរឬទេ ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំយល់ថាការបើកឲ្យអ្នកកាសែតចូលមកគឺជាការប្រសើរ ។ ខ្ញុំព្យាយាមប្រាប់គាត់ថា ការបិទមិនឲ្យអ្នកសារព័ត៌មានចូលមកក្នុងប្រទេសកម្ពុជានឹងបង្កើតឲ្យមានការមន្ទិលសង្ស័យថាគាត់មានអ្វីដែលលាក់បាំង ។ ខ្ញុំមិនដឹងថាគាត់ស្តាប់ខ្ញុំឬអត់ទេ ។

នៅតាមផ្លូវត្រឡប់ទៅផ្ទះសំណាក់របស់យើងវិញ ខ្មែរក្រហមសួរខ្ញុំថាតើខ្ញុំយល់ឃើញយ៉ាងម៉េចចំពោះ«បងទី១» ។ នេះជាលើកទីមួយដែលខ្ញុំបានឮពាក្យ«បងទី១» ខ្ញុំមានការភ្ញាក់ផ្អើលចំពោះពាក្យនេះនិងចំពោះសំណួរ ។ តាំងពីដើមទីមកបដិវត្តន៍កម្ពុជាខុសប្លែកពីបដិវត្តន៍ចិន វៀតណាម និងកូរ៉េត្រង់ថាគ្មានការលើកទឹកចិត្តឲ្យប្រជាជនគោរពបូជាមេដឹកនាំ ។ នៅក្នុងដំណើរទស្សនកិច្ចទាំងមូល យើងមិនបានឃើញរូបថតរបស់ ប៉ុល ពត នៅកន្លែងណាមួយទាល់តែសោះ ។ តាមពិតមេដឹកនាំខ្មែរក្រហមច្រើនតែមិនបញ្ចេញមុខនិងឈ្មោះ ។ ប្រជាជនកម្ពុជាជាច្រើនមិនដែលដឹងទាល់តែសោះថា ប៉ុល ពត ជានរណា ។ ក៏ប៉ុន្តែប្រហែលជាខ្មែរក្រហមមានគម្រោងឲ្យមានការគោរពបូជាថ្នាក់ដឹកនាំ ។ ការពិតដែលថាខ្មែរ-ក្រហមទុកជីវិតឲ្យ វ៉ាន់ ណាត នៅគូកទួលស្លែងឲ្យគូររូបរបស់ ប៉ុល ពត មានន័យថាបដិវត្តន៍មានគម្រោងឃោសនាឲ្យមានការគោរពបូជា ប៉ុល ពត ។

ដូច្នេះ តើខ្ញុំឆ្លើយយ៉ាងម៉េច? ប៉ុល ពត មិនបានបង្ហាញភាពអស្ចារ្យទាល់តែសោះ ។ គាត់និយាយយឺតៗ ហើយអ្វីដែលគាត់បាននិយាយផ្តល់ព័ត៌មានតិចតួចបំផុត ។ ក្នុងអំឡុងពេលជួបប្រជុំ កាម៉េរ៉ាវីដេអូថតយើងរហូត ហើយអាហារពេលល្ងាចក៏មានលក្ខណៈជាផ្លូវការ ។ ដូច្នេះខ្ញុំមិនអាចនិយាយថាគាត់អស្ចារ្យបានទេ ។ ខ្ញុំឆ្លើយតាមរបៀបគួរសមអំពីសមិទ្ធផលបដិវត្តន៍របស់គាត់ ។

មនុស្សជាច្រើនសួរគ្នាថាតើ ប៉ុល ពត មានជំងឺវិកលចរិតឬអត់ ។ ជួនកាលខ្ញុំឃើញមនុស្សពិភាក្សាគ្នាអំពីថាតើជំងឺវិកលចរិតរបស់គាត់ស្ថិតនៅក្នុងប្រភេទមួយណា ។ មានអ្នកខ្លះសួរខ្ញុំថា ពេលដែលខ្ញុំជួបជាមួយ ប៉ុល ពត តើខ្ញុំមានសម្គាល់ឃើញថាគាត់មានសភាពមិនប្រក្រតីដែរឬទេ ។ ខ្ញុំយល់ថា គាត់មើលទៅខុសប្រក្រតីបើនិយាយឲ្យសាមញ្ញ ។ ក៏ប៉ុន្តែគាត់ត្រូវតែប្រឈមមុខនឹងតុលាការនិងទទួលខុសត្រូវចំពោះអ្វីដែលគាត់បានធ្វើ ។ ខ្ញុំជឿជាក់ថា គាត់គិតថាខ្លួនគាត់មានសារសំខាន់ខណៈដែលការពិតគាត់មិនសូវសំខាន់ ។ នេះមិនមែនជាការសរុបសេចក្តីចេញអំពីការជួបប្រជុំរវាងខ្ញុំនិងគាត់ទេ ក៏ប៉ុន្តែផ្អែកទៅលើព័ត៌មានផ្សេងៗទៀត ។ ភាពមិនប្រក្រតីទាំងនេះចាប់ផ្តើមដំបូងបង្អស់ បន្ទាប់មកវានាំទៅដល់ការចាត់ទុកថាអ្នកដែលប្រឆាំងនឹងខ្លួនជាសត្រូវ ហើយចោទប្រកាន់ប្រជាជនថាជាភ្នាក់ងារបរទេស ។ ការមិនទុកចិត្តនេះស្រដៀងនៅនឹងរបបដឹកនាំរបស់ ស្តាលីន នៅសហភាពសូវៀត ។ ទាំង ស្តាលីន ទាំង ប៉ុល ពត មើលឃើញសត្រូវនៅគ្រប់ទីកន្លែងទាំងអស់ និងមិនអាចអត់ឱនចំពោះអ្នកដែលប្រឆាំងនឹងខ្លួនទោះជាក្នុងរូបភាពណាក៏ដោយ ។ ខ្ញុំគិតថាអំណាចធ្វើឲ្យមនុស្សដើរខុស ហើយនៅទីបំផុត ប៉ុល ពត ចង់ឲ្យប្រជាជនគោរពបូជាគាត់ និងមានបំណងដាក់តាំងរូបសំណាកដ៏ធំសម្បើមរបស់គាត់នៅវត្តភ្នំ ។ នៅពេលដែលកងទ័ពវៀតណាមកំពុងតែសម្រុកចូលទីក្រុងភ្នំពេញនៅថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៩ ប៉ុល ពត និយាយប្រាប់សម្តេចសីហនុ និងភ្ញៀវរបស់គាត់ អំពីការវាយរំលំវៀតណាម និងបន្តនិយាយរាប់ម៉ោងអំពីគម្រោងការដ៏សែនឆ្លាតរបស់គាត់ ។ គាត់បានបាត់ទំនាក់ទំនងជាមួយនឹងការពិតអស់ទៅហើយ ។



ទង់ជាតិស៊ុយអែដ

## ត្រឡប់ទៅប្រទេសស៊ុយអែដវិញ

នៅពេលដែលយើងចុះចតនៅស៊ុយអែដ យើងទាំងអស់គ្នាមានសុទិដ្ឋិនិយមចំពោះបដិវត្តន៍កម្ពុជា ។ យើងបានព្រមព្រៀងគ្នាថា នឹងមិនសរសេររបាយការណ៍មួយរួមគ្នាទេ ពីព្រោះបើធ្វើបែបនោះ យើងមិនអាចបញ្ចេញការយល់ឃើញខុសៗគ្នារបស់យើងបានទេ ។ យើងនឹងសរសេរដាច់ដោយឡែកពីគ្នា ដើម្បីបង្ហាញអំពីគោលគំនិតនិងយោបល់របស់យើងម្នាក់ៗ ។ ដូច្នោះ យើងសរសេរអត្ថបទសម្រាប់កាសែតរៀងៗខ្លួន ។ យើងបានធ្វើដំណើរទៅកាន់កន្លែងជាច្រើនដើម្បីផ្តល់បាឋកថានិងបញ្ចាំងរូបភាពអេឡិចត្រូនិក ។

សូម្បីតែកាលពីពេលនោះ យើងទាំងបួននាក់មានការយល់ឃើញខុសៗគ្នា ។ ខ្ញុំមិនពេញចិត្តចំពោះការជម្លៀសប្រជាជនចេញពីទីក្រុង ដូច្នេះខ្ញុំសរសេរខុសពីអ្នកផ្សេងត្រង់ចំណុចនេះ ។ អ្នកខ្លះមិនយល់ស្របចំពោះការប្រើប្រាស់ពលកម្មកុមារដូចដែលយើងបានឃើញ ។ តើមានអ្វីខុសគ្នាអំពីការប្រើប្រាស់ពលកម្មកុមារនៅបណ្តាប្រទេសផ្សេងៗទៀត នៅអាស៊ីនិងនៅប្រទេសស៊ុយអែដកាលពីមួយរយឆ្នាំមុន? បើពិនិត្យទៅលើគោលនយោបាយរបស់ខ្មែរក្រហម ការប្រើប្រាស់ពលកម្មកុមារគឺពិតជាខុសពីប្រទេសដទៃ ។

នៅចុងឆ្នាំ១៩៧៨ ខ្ញុំចាប់ផ្តើមបញ្ចេញឲ្យឃើញការមន្ទិលសង្ស័យរបស់ខ្ញុំ ។ មានជនភៀសខ្លួនជាច្រើន និងរឿងរ៉ាវស្តីពីអំពើឃោរឃៅដែលមិនអាចថាមិនពិត ។ ខ្ញុំកត់សម្គាល់ឃើញថា រឿងរ៉ាវមួយចំនួនមានលំនាំដូចជាអ្វីដែលយើងបានឃើញ ។ ខ្ញុំមិនអាចបន្តធ្វើមិនដឹងមិនឮ ហើយវាយតម្លៃថារឿងរ៉ាវទាំងអស់មិនពិតនោះទេ ។ ប្រហែលជាមានការចាប់ខ្លួនប្រជាជនយកទៅធ្វើទារុណកម្មនិងសម្លាប់ខណៈពេលដែលយើងកំពុងតែស្នាក់នៅក្នុងប្រទេសកម្ពុជា ។ ការស្នាក់នៅនិងធ្វើដំណើររបស់យើងនៅក្នុងប្រទេសកម្ពុជាមិនអនុញ្ញាតឲ្យយើងឃើញរូបភាពទាំងអស់នេះទេ ។

នៅខែមករា ឆ្នាំ១៩៧៩ វៀតណាមវាយលុកចូលទឹកដីកម្ពុជា ។ សមាគមមិត្តភាពស៊ុយអែដ-កម្ពុជាបង្វែរការយកចិត្តទុកដាក់ទៅលើការប្រឆាំងនឹងការឈ្លានពានរបស់វៀតណាមនៅក្នុងទឹកដីកម្ពុជា ។ ខ្ញុំផ្លាស់ទីលំនៅទៅភាគខាងជើងនៃប្រទេសស៊ុយអែដ ហើយក៏លែងជាសមាជិកនៃសមាគមទៀត ។ ការឈ្លានពានរបស់វៀតណាមកើតឡើងស្របពេលដែលខ្ញុំចាប់ផ្តើមផ្តល់បាឋកថាជាសាធារណៈ ដែលក្នុងនោះខ្ញុំនិយាយថា យើងបានយល់ខុសតាំងពីដើមរហូតមក ហើយយើងត្រូវតែទទួលស្គាល់និងនិយាយអំពីរឿងនេះ ។ សមាជិកផ្សេងទៀតនៅក្នុងក្រុមមិនបានទាក់ទងមកខ្ញុំអំពីរឿងនេះទេ ហើយខ្ញុំក៏មិនដឹងថាអ្នកទាំងនោះមានប្រតិកម្មយ៉ាងណាដែរ ។ អ្នកដទៃពិភាក្សាគ្នាអំពីការនាំយក ប៉ុល ពត មកដឹកនាំប្រទេសកម្ពុជាវិញនៅក្នុងអំឡុងពេលដ៏សំខាន់នេះ ។ ចម្លើយរបស់ខ្ញុំទៅនឹងបញ្ហានេះគឺថា កម្ពុជាប្រាកដជាបាត់បង់គុណធម៌អស់ប្រសិនបើប្រជាជនកម្ពុជាយល់ថា ប៉ុល ពត គួរតែត្រឡប់មកដឹកនាំប្រទេសវិញ ។ ខ្ញុំមិនយល់ថាប្រជាជនកម្ពុជាចង់ឲ្យវៀតណាមកាន់កាប់ប្រទេសរបស់ខ្លួនទេ ក៏ប៉ុន្តែខ្មែរក្រហមបានធ្វើទុក្ខបុកម្នេញប្រជាជនខ្លាំងពេករហូតដល់គ្មាននរណាម្នាក់ហ៊ានប្រថុយឲ្យ ប៉ុល ពត ត្រឡប់មកកាន់អំណាចម្តងទៀតឡើយ ។ ការណ៍នេះត្រូវតែពិចារណាឲ្យបានដិតដល់ប្រសិនបើចង់រើបម្រះ ។ ខ្ញុំក៏យល់ថា វាគួរឲ្យចាប់អារម្មណ៍ថា ស្ទើរតែគ្រប់ពេលវេលានៅក្នុងប្រវត្តិសាស្ត្រនៃរបបកុម្មុយនីស្ត នៅពេលដែលនរណាម្នាក់ចង់និយាយអំពីកំហុសដែលបានកើតឡើង អ្នកនោះតែងតែបានទទួលចម្លើយថាមិនទាន់ដល់ពេលវេលាទេ ។ តែងតែមានមូលហេតុនេះមូលហេតុនោះដើម្បីលាក់បាំងកំហុសទាំងអស់ ។

មួយឆ្នាំក្រោយមក ខ្ញុំសម្រេចចិត្តចូលរួមជាសមាជិកគណៈកម្មាធិការនាយករបស់សមាគមជាថ្មីម្តងទៀត ។ សមាគមអញ្ជើញខ្ញុំត្រឡប់មកវិញដើម្បីឲ្យល្អមើល ពីព្រោះអ្នកទាំងនោះយល់ថា ប្រសិនបើមានសមាជិកដែលមាននិន្នាការប្រឆាំង ឧទាហរណ៍ដូចជាខ្ញុំនេះជាដើម នោះនឹងធ្វើឲ្យសមាគមមានប្រជាប្រិយភាព ។ ខ្ញុំប្រាប់ទៅសមាគមថា ដើម្បីទទួលបានការទុកចិត្តជាថ្មីសមាគមត្រូវការលាងខ្លួនឲ្យជ្រះអំពីកំហុសដែលពាក់ព័ន្ធនឹង ប៉ុល ពត ។ ប៉ុន្មានឆ្នាំក្រោយមកសមាគមក៏រលាយ ។ យើងម្នាក់ៗបែកគ្នាទៅតាមផ្លូវរៀងៗខ្លួន និងមិនដែលជួបគ្នាជាក្រុមចាប់តាំងពីពេលនោះមក ។ យើងមានយោបល់ខុសៗគ្នាចំពោះអ្វីដែលបានកើតឡើង ហើយយើងធ្វើសេចក្តីសន្និដ្ឋានខុសៗគ្នា ។ ពាក្យពេចន៍និងយោបល់ទាំងអស់នៅក្នុងសៀវភៅរូបភាពនេះគឺជាការយល់ឃើញរបស់ខ្ញុំតែម្នាក់ ។

ហ៊ុនណា បឺយស្រ្តុម, ខែសីហា ឆ្នាំ២០០៨

ឥឡូវនេះលោកអ្នកបានឃើញអ្វីដែលយើងបានឃើញនៅក្នុងដំណើរទស្សនកិច្ចរយៈពេលចំនួន ១៨ថ្ងៃនៅប្រទេសកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ដូចដែលខ្ញុំបាននិយាយរួចមកហើយនៅក្នុងសេចក្តីផ្តើម ខ្ញុំយល់ថាដំណើរទស្សនកិច្ចនោះគឺជាកំហុសធ្ងន់មួយពីព្រោះ វាគឺជាផ្នែកមួយនៃការឃោសនានយោបាយរបស់ខ្មែរក្រហម ។

យើងមិនអាចត្រឡប់ក្រោយវិញបានទេ ។ ខ្ញុំបានរៀនសូត្រជាច្រើនអំពីកំហុសរបស់ខ្ញុំនៅក្នុងការវិនិច្ឆ័យរបបខ្មែរក្រហមកាលពីពេលនោះ ។ ប្រហែលជាខ្ញុំអាចចែករំលែកមេរៀនប្រវត្តិសាស្ត្រមួយចំនួនជាមួយអ្នកដទៃ ដើម្បីកុំឲ្យមានរឿងបែបនេះកើតឡើងម្តងទៀត ។ ប្រហែលជាមានមេរៀនប្រវត្តិសាស្ត្រមួយចំនួនទៀតដែលខ្ញុំមិនទាន់យល់ច្បាស់ ហើយលោកអ្នកអាចមើលឃើញថាខ្ញុំមិនទាន់អាចធ្វើសេចក្តីសន្និដ្ឋានបាននៅឡើយ ។

បទពិសោធន៍របស់ខ្ញុំបានបង្រៀនខ្ញុំថា សិទ្ធិជាមូលដ្ឋានមួយចំនួនរបស់មនុស្សមិនអាចលុបបំបាត់បានទេគឺ ៖

- សិទ្ធិក្នុងការគិតនិងបញ្ចេញមតិយោបល់
- សិទ្ធិក្នុងការគោរពនិងប្រតិបត្តិសាសនាណាមួយ
- សិទ្ធិក្នុងការធ្វើដំណើរ

ខ្ញុំក៏សង្ឃឹមដែរថា ខ្ញុំបានប្រែក្លាយទៅជាមនុស្សដែលមានការសង្ស័យខ្លះចំពោះពាក្យដែលថា «អ្វីៗទាំងអស់ត្រូវបានដោះស្រាយ» ចំពោះមេដឹកនាំដែលអះអាងថាខ្លួនបានមើលឃើញការពិតគ្រប់យ៉ាង និងចំពោះការអះអាងដែលថាអាចដោះស្រាយគ្រប់បញ្ហាបានយ៉ាងឆាប់រហ័ស ។

ខ្ញុំនៅតែមានជំនឿចិត្តថាយើងនឹងមានពិភពលោកមួយដែលស្មើភាពនិងយុត្តិធម៌សម្រាប់មនុស្សទាំងអស់គ្នាប្រសើរជាងពិភពលោកដែលយើងកំពុងតែរស់នៅសព្វថ្ងៃ ។

ខ្ញុំសូមខមាទោសចំពោះអ្នកដែលទទួលរងការប៉ះទង្គិចដោយសារតែការគាំទ្ររបស់ខ្ញុំចំពោះខ្មែរក្រហម និងជាពិសេស ចំពោះអ្នកដែលរងគ្រោះដោយផ្ទាល់នៅក្រោមរបបនោះ ។

ស៊ុយអែដ, ខែមេសា ឆ្នាំ២០០៨



ហុនណា បឺយស្រ្តម នៅខេត្តកំពង់ចាម ក្នុងឆ្នាំ១៩៧៨
រូបថតដោយ ហេដា អេកឺវ៉ល

## ឆ្នាំ១៩៧៨

ក្នុងឆ្នាំ១៩៧៨ ខ្ញុំមានអាយុ២៧ឆ្នាំនិងមានកូនពីរនាក់ ។ ខ្ញុំបានចូលរួមចំណែកយ៉ាងសកម្មក្នុងចលនាប្រឆាំងនឹងសង្រ្គាមនៅវៀតណាម ឡាវ និងកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំ ។ នៅប្រទេសស៊ុយអែដ ចលនានេះមានសកម្មភាពខ្លាំងក្លា អាចថាខ្លាំងជាងបណ្តាប្រទេសណាៗទាំងអស់នៅលោកខាងលិច ។ យុវជនរាប់ពាន់នាក់លះបង់ពេលវេលាទាំងអស់របស់ខ្លួនធ្វើការងារដើម្បីប្រឆាំងនឹងសង្រ្គាមអាមេរិក ។ ខ្ញុំនៅក្នុងចំណោមយុវជនទាំងនោះ ។ ខ្ញុំលះបង់យុវវ័យទាំងអស់របស់ខ្ញុំដើម្បីបុព្វហេតុតែមួយនេះ ។

ក្រោយមកទៀត ខ្ញុំក៏ដូចជាអ្នកដទៃទៀតត្រូវបានទាក់ទាញដោយទស្សនវិជ្ជាកុម្មុយនីស្តម៉ៅនិយម ។ យើងជឿជាក់ថា បដិវត្តន៍សហភាពសូវៀតមិនទាន់បរិសុទ្ធនៅឡើយ ហើយបដិវត្តន៍ចិនក៏ខុសប្លែកពីគ្នា ។ មនុស្សមួយចំនួនចាប់អារម្មណ៍ចំពោះបដិវត្តន៍កម្ពុជាដែលយើងយល់ថាថ្មីនិងបរិសុទ្ធ ហើយការចាប់អារម្មណ៍នេះចេះតែកើនឡើង ។

ខ្ញុំគឺជាសមាជិកបក្សម៉ៅនិយមនោះរហូតដល់ឆ្នាំ១៩៧៩ទើបចាកចេញ ហើយចាប់ផ្តើមបើកចំហជាសាធារណៈ នូវគំនិតដែលផ្ទុយពីការយល់ឃើញពីពេលមុនរបស់ខ្ញុំពីព្រោះតែខ្ញុំយល់ថាយើងបានយល់ខុសតាំងពីដើមមក ។

## បច្ចុប្បន្ន

បច្ចុប្បន្នខ្ញុំអាយុ៥៧ឆ្នាំ និងធ្វើការងារជាទីប្រឹក្សាកែតម្រង់ផ្លូវអ្នកដែលញៀនថ្នាំនិងធ្លាប់ប្រព្រឹត្តបទឧក្រិដ្ឋ ។ ខ្ញុំរស់នៅជាមួយប្រពន្ធរបស់ខ្ញុំនៅ វ៉ាលិនធូណា ភាគខាងជើងទីក្រុងស្តុកខូម ។ កូនៗទាំងប្រាំនាក់របស់ខ្ញុំធំពេញវ័យនិងបានបែកផ្ទះរៀងៗខ្លួន ។

ខ្ញុំលែងជាមនុស្សសកម្មនៅក្នុងគណបក្សនយោបាយទៀតហើយ ព្រោះខ្ញុំមិនឃើញមានគណបក្សណាមួយដែលពេញចិត្តសោះ ។ ខ្ញុំនៅតែជឿជាក់ថា យើងអាចបង្កើតពិភពលោកមួយដែលស្មើភាពនិងយុត្តិធម៌ ក៏ប៉ុន្តែខ្ញុំមិនជឿទៅលើដំណោះស្រាយតាមបែបម៉ៅនិយមដែលខ្ញុំធ្លាប់បានជឿកាលពីឆ្នាំ១៩៧៨ឡើយ ។

## «វេទិកាប្រវត្តិសាស្ត្ររស់» នៅប្រទេសស៊ុយអែដ

វេទិកាប្រវត្តិសាស្ត្ររស់គឺជាភ្នាក់ងាររដ្ឋាភិបាលដែលបានទទួលការចាត់តាំងឲ្យធ្វើការងារទៅលើប្រធានបទពាក់ព័ន្ធទៅនឹងលទ្ធិប្រជាធិបតេយ្យ និទ្ទណ្ឌភាព និងការគោរពសិទ្ធិមនុស្ស ដោយយកប្រវត្តិសាស្ត្រនៃការសម្លាប់ជនជាតិជ្វីហ្វនៅអឺរ៉ុបធ្វើជាចំណុចចាប់ផ្ដើម ។ យើងចង់ឲ្យមានកំណែទម្រង់សម្រាប់អនាគតតាមរយៈការផ្សព្វផ្សាយចំណេះដឹងអំពីផ្នែកអវិជ្ជមាននៃប្រវត្តិសាស្ត្ររបស់មនុស្សជាតិ ។ យើងមើលទៅដល់ឫសគល់នៃបញ្ហា ហើយឆ្លុះបញ្ចាំងទៅលើបញ្ហាយុត្តិធម៌ បញ្ហាមនុស្ស និងការទទួលខុសត្រូវរបស់បុគ្គល ។

យើងសួរខ្លួនឯងថា តើហេតុអ្វីក៏រឿងរ៉ាវទាំងនោះអាចកើតឡើងបាន ហើយនៅតែបន្តកើតឡើងទៀត ។

គោលដៅរបស់យើងគឺលើកទឹកចិត្តប្រជាជនឲ្យចូលរួមចំណែកធ្វើការងារដើម្បីភាពស្មើគ្នានៃមនុស្សទាំងអស់ ។ យើងលើកទឹកចិត្តឲ្យមនុស្សស្ដាប់ យល់ និងធ្វើសកម្មភាព ។ ដើម្បីធ្វើបែបនេះបានទាមទារមិនត្រឹមតែការផ្សព្វផ្សាយព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែយើងត្រូវតែបង្កើតគំនិតថ្មីតាមដែលអាចធ្វើបាន ។

វេទិកាប្រវត្តិសាស្ត្ររស់នឹងបើកបង្ហាញពិព័រណ៍រូបថតនេះនៅការិយាល័យរបស់ខ្លួននៅទីក្រុងស្តុកខូម ។ ពិព័រនេះនឹងធ្វើដំណើរជុំវិញប្រទេសស៊ុយអែដចាប់ពីឆ្នាំ២០០៩ ។

សូមមើលគេហទំព័រ ៖ www.levandehistoria.se

## មជ្ឈមណ្ឌលឯកសារកម្ពុជា

មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាវិទ្យាស្ថានស្រាវជ្រាវឯករាជ្យនៅប្រទេសកម្ពុជាដែលធ្វើការងារដើម្បីលើកកម្ពស់ការចងចាំនិងយុត្តិធម៌ ។ យើងមានបំណងជួយប្រជាជនកម្ពុជាព្យាបាលរបួសពីអតីតកាលតាមរយៈការប្រមូលចងក្រងឯកសារ ការសិក្សាស្រាវជ្រាវ និងការចែករំលែកប្រវត្តិសាស្ត្ររបបខ្មែរក្រហម ។ យើងបានរួមចំណែកនៅក្នុងការពង្រឹងនីតិរដ្ឋនិងទប់ស្កាត់ការរំលោភសិទ្ធិមនុស្សនៅប្រទេសកម្ពុជានិងប្រទេសដទៃៗទៀត តាមរយៈការជំរុញឲ្យមានការទទួលខុសត្រូវ និងការបង្រៀនអំពីមូលដ្ឋានគ្រឹះនៃច្បាប់និងយុត្តិធម៌ ។

ដើម្បីឲ្យប្រាកដថាយើងនៅតែបំពេញការងារនេះក្នុងពេលអនាគតយើងកំពុងតែរៀបចំបង្កើតវិទ្យាស្ថានអចិន្ត្រៃយ៍មួយដែលយើងដាក់ឈ្មោះថា «វិទ្យាស្ថានស្លឹករឹត» ។ វិទ្យា-ស្ថានស្លឹករឹត នឹងដើរតួនាទីជាមជ្ឈមណ្ឌលឯកសារកម្ពុជាអចិន្ត្រៃយ៍ ដែលរួមមានមជ្ឈមណ្ឌលស្រាវជ្រាវនិងបណ្ដុះបណ្ដាល បណ្ណាល័យ សារមន្ទីរ និងមជ្ឈមណ្ឌលសារព័ត៌មាន ។ និយាយជារួម មជ្ឈមណ្ឌលស្លឹករឹត ដើរតួជាវិទ្យាស្ថានគំរូមួយដែលប្រឆាំងនឹងអំពើប្រល័យពូជសាសន៍នៅកម្ពុជានៅអាស៊ី និងនៅទូទាំងពិភពលោក ។ ឈ្មោះដែលយើងជ្រើសរើសដាក់ឲ្យវិទ្យាស្ថានឆ្លុះបញ្ចាំងគោលដៅចម្បងរបស់យើងនិងកេរ្ដិ៍ដំណែលវប្បធម៌ខ្មែរ ។ ស្លឹករឹត គឺជាស្លឹកទ្រាំងហាលស្ងួត ដែលគ្រួសារព្រះរាជឬអ្នកប្រាជ្ញប្រើសម្រាប់កត់ត្រាហេតុការណ៍ប្រវត្តិសាស្ត្រ វប្បធម៌ និងគម្ពីរសាសនា ជាមធ្យោបាយថែរក្សាវប្បធម៌ និងចែករំលែកចំណេះដឹងទៅមនុស្សជំនាន់ក្រោយ ។ ស្លឹករឹត ជាតំណាងឲ្យចំណងវប្បធម៌និងប្រវត្តិសាស្ត្ររវាងកម្ពុជានិងប្រទេសជិតខាងដូចជាភូមា



ស្លឹករឹតនៅក្នុងសតវត្សទី១៨ នៅប្រទេសកម្ពុជា

ថៃ ឡាវ និងឥណ្ឌូនេស៊ី ដែលនៅតែបន្តប្រើប្រាស់ស្លឹករឹតដល់សព្វថ្ងៃក្នុងការកត់ត្រាគម្ពីរសាសនា ។ នៅទូទាំងទ្វីបអាស៊ី ស្លឹករឹត តំណាងឲ្យចំណេះដឹងនិងឆន្ទៈរបស់មនុស្សក្នុងការថែរក្សាកេរ្ដិ៍ដំណែលរបស់ប្រទេសនៅក្នុងដំណាក់កាលលំបាក ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្ដល់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជានូវដីមួយកន្លែងនៅក្នុងទីក្រុងភ្នំពេញ និងផ្ដល់សិទ្ធិឲ្យមជ្ឈមណ្ឌលក្នុងការបណ្ដុះបណ្ដាលមនុស្សជំនាន់ក្រោយ ។ យើងកំពុងតែធ្វើការងារជាមួយស្ថាបត្យករកំពូលថ្នាក់ជាតិនិងអន្តរជាតិដើម្បីរៀបចំប្លង់វិទ្យាស្ថាន និងរៃអង្គាសថវិកាដើម្បីចំណាយទៅលើការសាងសង់ វិទ្យាស្ថានស្លឹករឹត និងដើម្បីការចំណាយទៅលើដំណើរការរបស់វិទ្យាស្ថាន ។

## ទស្សនវិស័យរបស់យើងសម្រាប់ វិទ្យាស្ថានស្លឹករឹត

តាំងពីឆ្នាំ១៩៩៥ យើងបានកសាងកេរ្តិ៍ឈ្មោះជាវិទ្យាស្ថាននាំមុខលំដាប់អន្តរជាតិក្នុងការខិតខំប្រឹងប្រែងដ៏យូរអង្វែងដើម្បីលើកកម្ពស់ការចងចាំនិងយុត្តិធម៌ ។ គោលដៅរបស់យើងគឺផ្តោតជាសំខាន់ទៅលើអនាគតច្រើនជាងអតីតកាល ។ វិទ្យាស្ថានស្លឹករឹត នឹងបូជាកម្លាំងកាយចិត្តដើម្បីគោលដៅនេះ ។

- ក្នុងនាមជាសារមន្ទីរ វិទ្យាស្ថាននឹងលើកតម្កើងការចងចាំអំពីអ្នកដែលបានបាត់បង់ជីវិត ជំរុញឲ្យមានការផ្សះផ្សានិងការអភ័យទោស និងបង្ហាញឥទ្ធិពលនៃវប្បធម៌ខ្មែរក្នុងការខំប្រឹងប្រែងដើម្បីរស់និងជម្នះទៅនឹងកេរ្តិ៍ដំណែលដ៏គួរឲ្យភ័យខ្លាចរបស់ខ្មែរក្រហម ។
- ក្នុងនាមជាមជ្ឈមណ្ឌលស្រាវជ្រាវដែលមានបណ្ណាល័យបំពាក់ទៅដោយប្រព័ន្ធសេវាកម្មទំនើប យើងនឹងបន្តចងក្រង រៀបចំ វិភាគ និងថែរក្សា ព័ត៌មានអំពីរបបកម្ពុជាប្រជាធិបតេយ្យនិងរបបផ្សេងៗទៀតដែលបង្កទុក្ខវេទនាដល់មនុស្សជាតិ ។ ការស្រាវជ្រាវកម្រិតខ្ពស់នៅវិទ្យាស្ថាននឹងលើកកម្ពស់ការទទួលខុសត្រូវនិងលើកទឹកចិត្តឲ្យមានការយល់ដឹងកាន់តែប្រសើរអំពីប្រវត្តិសាស្ត្រកម្ពុជានិងប្រទេសដទៃទៀតដែលបែកបាក់ដោយសារជម្លោះនិងសោកនាដកម្ម ។
- ក្នុងនាមជាមជ្ឈមណ្ឌលអប់រំ វិទ្យាស្ថាននឹងបង្រៀនប្រជាជនកម្ពុជានិងភ្ញៀវបរទេសអំពីមេរៀនប្រវត្តិសាស្ត្រនិងអំពីមូលដ្ឋានគ្រឹះនៃច្បាប់និងសិទ្ធិមនុស្ស ដែលត្រូវការជាចាំបាច់ដើម្បីកសាងអនាគតមួយដែលប្រសើរ ។
- ក្នុងនាមជាមជ្ឈមណ្ឌលសារព័ត៌មាន វិទ្យាស្ថាននឹងផ្សព្វផ្សាយចំណេះដឹងឲ្យបានទូលំទូលាយ និងចូលរួមចំណែកក្នុងការពិភាក្សាប្តូរយោបល់តាមបែបប្រជាធិបតេយ្យពិតប្រាកដអំពីតម្រូវការដើម្បីបង្កើតសង្គមមួយដែលមានយុត្តិធម៌ ។

ការអប់រំគឺជាកិច្ចការស្នូលដែលផ្សារភ្ជាប់ទៅគ្រប់កិច្ចការរបស់វិទ្យាស្ថាន ។ សូម្បីតែនៅពេលដែលតុលាការខ្មែរក្រហមចប់រួចរាល់ជាស្ថាពរក៏ដោយ ក៏ការស្រាវជ្រាវ និងបណ្តុះបណ្តាលនៅតែត្រូវបន្តច្រើនឆ្នាំទៅមុខទៀតដែរ ដើម្បីឲ្យមានការយល់ដឹងគ្រប់ជ្រុងជ្រោយអំពីសោកនាដកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ កម្ពុជាអាចផ្សះផ្សាបានលុះត្រាតែមានការយល់ដឹងច្បាស់លាស់និងមិនលម្អៀងអំពីប្រវត្តិសាស្ត្រមួយ ។ ជាងនេះទៅទៀត កម្ពុជាអាចទប់ស្កាត់ការរំលោភសិទ្ធិមនុស្សនៅពេលអនាគត និងកសាងនីតិរដ្ឋមួយបានលុះត្រាតែមានការយល់ដឹងអំពីមូលហេតុនិងផលវិបាកនៃអំពើប្រល័យពូជសាសន៍ ។ វិទ្យាស្ថានស្លឹករឹត នឹងដើរតួនាទីដ៏សំខាន់នៅក្នុងដំណើរការទាំងអស់នេះ ដែលទាក់ទងនឹងការផ្សះផ្សានិងអភិវឌ្ឍសង្គម ។

# សេចក្តីថ្លែងអំណរគុណ

សៀវភៅនេះបោះពុម្ពឡើងក្រោមជំនួយនិងការជ្រោមជ្រែងរបស់បុគ្គលនិងវិទ្យាស្ថានមួយចំនួន ។ បុគ្គលសំខាន់បំផុតដែលគាំទ្រខ្ញុំគឺជនរងគ្រោះនៃរបបខ្មែរក្រហមដែលភាគច្រើនខ្ញុំមិនបានស្គាល់ ប៉ុន្តែគាត់បានបញ្ចេញអំពីរឿងរ៉ាវនៃការជីវិតរបស់គាត់នៅក្រោមរបបខ្មែរក្រហម ។ រឿងរ៉ាវដែលគាត់បានរៀបរាប់ប្រាប់ បានធ្វើឲ្យខ្ញុំមានការយល់ដឹងប្រសើរជាងមុនអំពីរឿងរ៉ាវដ៏គួរឲ្យភ័យរន្ធត់ដែលលាក់បាំងនៅពីក្រោយមុខមាត់ស្អាតស្អំរបស់របបខ្មែរក្រហមដែលយើងបានឃើញក្នុងអំឡុងពេលទស្សនកិច្ចរបស់យើង ។

ខ្ញុំក៏សូមថ្លែងអំណរគុណលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ គាត់គឺជាអ្នកផ្តួចផ្តើមគំនិតក្នុងការបោះពុម្ពផ្សាយសៀវភៅនេះនិងការរៀបចំតាំងពិព័រណ៍ និងបានជួយកែសម្រួលសៀវភៅនេះ ។ ថវិកាសម្រាប់បោះពុម្ពសៀវភៅនេះបានមកពីភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់សហរដ្ឋអាមេរិក ភ្នាក់ងារអភិវឌ្ឍអន្តរជាតិរបស់ប្រទេសស៊ុយអែដ និងវេទិកាប្រវត្តិសាស្ត្ររស់នៅប្រទេសស៊ុយអែដ ។ អរគុណចំពោះ ហ៊ុយ សោភ័ណ និង សារ៉ា ឌីកកិន ដែលបានរៀបចំគម្រោងថវិកា ។ អរគុណចំពោះ ចូអែល ប្រ៊ីងគ្លី ដែលបានជួយកែសម្រួល ។ អរគុណចំពោះ អ៊ីវ៉ានទី វ៉ុង ដែលបានរៀបចំក្រាហ្វិកសៀវភៅនេះ ។ អរគុណចំពោះ ស៊ឹម សុភ័ក្រ្ត និង គីម សុវណ្ណដានី ដែលជួយចាត់ចែងការបោះពុម្ពផ្សាយ ។ អរគុណចំពោះ សាន់ កល្យាណ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា និង លី ដារ៉ាវុធ នៅវិទ្យាស្ថានវៃយំ ដែលបានរៀបចំការតាំងពិព័រណ៍នៅក្នុងប្រទេសកម្ពុជា ។ អរគុណ សើ សាយ្យាណា និង ម៉ម កល្យានី ដែលបានរៀបចំការតាំងពិព័រណ៍នៅឯការិយាល័យអង្គជំនុំជម្រះវិសាមញ្ញក្នុងប្រព័ន្ធតុលាការកម្ពុជា ។ អរគុណ ហេដា អេគីវ៉ែល ដែលបានអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់រូបថតទាំងនេះ ។

ISBN-9789995060152

ឯកសារបកប្រែទី៧នៃមជ្ឈមណ្ឌលឯកសារកម្ពុជា | www.dccam.org